ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រអភិវឌ្ឍន៍ វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា ២០២៥ - ២០៣៥




បានទទួលការអនុម័តក្នុងកិច្ចប្រជុំក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
នាសម័យប្រជុំលើកទី២០ អាណត្តិទី១
ថ្ងៃចន្ទ ៤កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ត្រូវនឹងថ្ងៃទី៤ ខែវិច្ឆិកា គ.ស.២០២៤

រៀបចំដោយ
និយ័តករគណនេយ្យនិងសវនកម្ម

២០២៤

# បុព្វកថា

ក្នុងរយៈពេល ២៥ឆ្នាំចុងក្រោយនេះ ក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាពពេញផ្ទៃប្រទេស ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បាននាំមកជូនប្រទេសជាតិ និងប្រជាជន តាមរយៈនយោបាយឈ្នះឈ្នះ កម្ពុជាបន្តសម្រេចបាននូវសមិទ្ធផលធំៗជាច្រើន ក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងបានផ្លាស់ប្តូរមុខមាត់កម្ពុជាគួរជាទីមោទនៈ តាមរយៈការអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំងបួនដំណាក់កាល ព្រមទាំងគោលនយោបាយនិងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធផ្សេងទៀត។ ការដាក់ចេញគោលនយោបាយត្រឹមត្រូវ មុតស្រួច និងទាន់ពេល បានជំរុញឱ្យកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រាប្រមាណ ៧% ជាមធ្យមក្នុងមួយឆ្នាំ ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ មុនការមកដល់នៃជំងឺកូវីដ-១៩ រហូតបានប្រែក្លាយកម្ពុជាពីប្រទេសចំណូលទាបទៅជាប្រទេសចំណូលមធ្យមកម្រិតទាប កាលពីឆ្នាំ២០១៥។ លើសពីនេះ ជាមួយនឹងមូលដ្ឋានសង្គម-សេដ្ឋកិច្ចដ៏រឹងមាំប្រកបដោយចីរភាព បរិយាបន្ន សមធម៌ និងភាពធន់នឹងវិបត្តិសេដ្ឋកិច្ច កម្ពុជាត្រូវបានប៉ាន់ស្មានថាអាចសម្រេចបានកំណើនប្រមាណ ៦% ក្នុងមួយឆ្នាំ បន្ទាប់ពីទទួលរងការបង្អាក់ដោយវិបត្តិជាសកលនៃជំងឺកូវីដ-១៩ និងទោះបីជាកម្ពុជាត្រូវបន្តជួបប្រឈមនឹងសភាពការណ៍សកលដែលមានភាពមិនប្រាកដប្រជាខ្ពស់ក៏ដោយ ក្នុងនោះរួមមានភាពតានតឹងនៃស្ថានភាពភូមិសាស្ត្រនយោបាយ ពិសេសសង្គ្រាមរវាងរុស្ស៊ីនិងអ៊ុយក្រែន ការប្រយុទ្ធរវាងអ៊ីស្រាអែលនិងហាម៉ាស់ និងកំណើនយឺតនៃសេដ្ឋកិច្ចសកល ព្រមទាំងការថមថយនៃតម្រូវការនៅតាមបណ្តាប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា ជាដើម។

ក្នុងបរិការណ៍នេះ កម្ពុជាត្រូវសម្របខ្លួនជាប្រចាំតាមនិន្នាការប្រែប្រួលសកល ដែលទាមទារនូវការយកចិត្តទុកដាក់ខ្ពស់ចំពោះការលើកកម្ពស់ភាពជាអ្នកដឹកនាំ និងសមត្ថភាពស្ថាប័នគ្រប់កម្រិត ដោយផ្សារភ្ជាប់នឹងការធានាបាននូវគោលនយោបាយសមស្រប និងសមត្ថភាពអនុវត្តជាក់ស្តែង លទ្ធផលការងារ និងការទទួលខុសត្រូវដើម្បីឆ្លើយតបទៅនឹងអាទិភាពសំខាន់ៗនៅក្នុងដំណាក់កាលថ្មី រួមមានជាអាទិ៍៖ ការពង្រឹងអភិបាលកិច្ច ការទ្រទ្រង់កំណើននិងការធ្វើទំនើបកម្មសេដ្ឋកិច្ច ការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគនិងធុរកិច្ច ការបង្កើតការងារទាំងគុណភាព និងបរិមាណ ការលើកស្ទួយវិស័យឯកជននិងសហគ្រិនភាព និងការកសាងមូលធនមនុស្ស។



នៅក្នុងក្របខណ្ឌនៃទស្សនវិស័យនេះ និងផ្អែកតាមកម្មវិធីនយោបាយរបស់ខ្លួន រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ស្វាហាប់ និងឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជាអគ្គមគ្គុទ្ទេសក៍វ័យក្មេង ដ៏ឆ្នើម និងពោរពេញដោយសមត្ថភាព ចំណេះដឹង និងថាមពល បានដាក់ចេញនូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដោយបាន កំណត់យក អាទិភាពគន្លឹះ៥គឺ៖ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា ជាពិសេស គឺ បច្ចេកវិទ្យាឌីជីថល សម្រាប់ឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤ និងបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ចនិងសង្គមកម្ពុជា ក៏ដូចជាឆ្លើយតបនឹងតម្រូវការក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ចដែលជាគ្រឹះនិងជាមធ្យោបាយដ៏សំខាន់នៃការសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនិងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) បានដាក់ចេញជាបន្តបន្ទាប់នូវច្បាប់ លិខិតបទដ្ឋាន យុទ្ធសាស្ត្រគាំទ្រនិងប្រទាក់ក្រឡាគ្នាដែលមានការពាក់ព័ន្ធនឹងវិស័យគណនេយ្យនិងសវនកម្ម មានជាអាទិ៍៖ ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម, ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា(ថ្មី)ច្បាប់ស្តីពីសារពើពន្ធ(ថ្មី), ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ(ថ្មី), យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥, យុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា២០២១-២០៣១, និងផែនការអភិវឌ្ឍន៍ស្ថាប័នបច្ចុប្បន្នកម្មរយៈពេល១០ឆ្នាំ(២០២១-២០៣០) របស់និយ័តករគណនេយ្យនិងសវនកម្ម (**ន.គ.ស.**) ដើម្បីបង្កើតក្របខណ្ឌគ្រប់គ្រងរឹងមាំ លើកកម្ពស់វិស័យឯកជននិងសាធារណៈ និងបណ្តុះវប្បធម៌គណនេយ្យនិងសវនកម្មដែលក្នុងនោះរួមមាន៖ ការកាន់បញ្ជីគណនេយ្យត្រឹមត្រូវ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន ការធ្វើសវនកម្មឯករាជ្យលើរបាយការណ៍ហិរញ្ញវត្ថុតាមច្បាប់កំណត់ និងការដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុនៅ **ន.គ.ស.**។

យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា ២០២៥-២០៣៥ នេះ ឆ្លុះបញ្ចាំងពីសមិទ្ធផលដែលសម្រេចបាន បញ្ហាប្រឈមដែលវិស័យកំពុងជួបប្រទះ និងការដាក់ចេញសកម្មការងារជាយុទ្ធសាស្ត្រដែលត្រូវអនុវត្តដើម្បីដោះស្រាយបញ្ហាប្រឈម ដោយការធ្វើអាទិភាវូបនីយកម្មសកម្មភាពជាយុទ្ធសាស្ត្រ ដែលក្នុងនោះរួមមាន៖ ការអភិវឌ្ឍស្ថាប័ន ការអភិវឌ្ឍមូលធនមនុស្សក្នុងវិស័យគណនេយ្យនិងសវនកម្ម សុខដុមនីយកម្ម ស្តង់ដាបច្ចេកទេស ការលើកកម្ពស់កម្រិតអនុលោមភាព ការលើកកម្ពស់គុណភាពសេវាសវនកម្ម និងការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាគាំទ្របច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងបរិការណ៍សេដ្ឋកិច្ចឌីជីថល។

ក្នុងនាមក្រុមប្រឹក្សា **អ.ស.ហ.** និងរូបខ្ញុំផ្ទាល់ ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់ **ន.គ.ស.** ដែលបានរៀបចំ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្ម នៅកម្ពុជា ២០២៥-២០៣៥**" នេះឡើង ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ ទន្ទឹមនេះ ខ្ញុំសូមថ្លែងអំណរគុណ ជូនឯកឧត្តម **រស់ សីលវ៉ា** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា **អ.ស.ហ.** ឯកឧត្តម **ខី តាឃី** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាសមាជិកក្រុមប្រឹក្សា **អ.ស.ហ.** និងឯកឧត្តម **ម៉ី វ៉ាន់** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** ព្រមទាំងថ្នាក់ដឹកនាំបច្ចេកទេសនៃ **អ.ស.ហ.** និងជាពិសេស ឯកឧត្តម **ម៉ូ ថារិន** អគ្គនាយកនៃ **ន.គ.ស.** ដែលបានដឹកនាំដោយផ្ទាល់ និងលោក លោកស្រី ជាអគ្គនាយករង ថ្នាក់ដឹកនាំ និងមន្ត្រីនៃ **ន.គ.ស.** និងភាគីពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកក្នុងការរៀបចំ និងផ្តល់ធាតុចូលលើឯកសារ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្ម នៅកម្ពុជា ២០២៥-២០៣៥**" បានគ្រប់ជ្រុងជ្រោយ និងក្លាយជាឯកសារយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងវិស័យឯកជននឹងបន្តចូលរួមយ៉ាងសកម្មក្នុងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្ម ឱ្យសម្រេចបានលទ្ធផលតាមការគ្រោងទុកតាមដំណាក់កាលនីមួយៗ ក្នុងបុព្វហេតុនៃការកសាងឱ្យបាននូវប្រព័ន្ធគណនេយ្យនិងសវនកម្មមួយដ៏រឹងមាំដែលអាចធានាបានគណនេយ្យភាព តម្លាភាព និងភាពជឿទុកចិត្តបាន។

ថ្ងៃ ចន្ទ ៨ រោច ខែ មិគសិរ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ ធ្នូ គ.ស. ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា

**បញ្ជីពាក្យកាត់**.......................................................................... i
**សេចក្ដីសង្ខេបប្រតិបត្តិ** .......................................................................... ii
**ដ្យាក្រាមបង្ហាញពីទំនាក់ទំនងរបស់ភាគីពាក់ព័ន្ធក្នុងវិស័យគណនេយ្យ និងសវនកម្ម** .......................................................................... iv
**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា**.................. ១
**១. សេចក្ដីផ្ដើម**.......................................................................... ១
**២. ស្ថានភាពបច្ចុប្បន្ន** ..........................................................................២
២.១. ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ..........................................២
២.២. ក្របខណ្ឌគោលនយោបាយវិស័យគណនេយ្យនិងសវនកម្ម ............................ ៤
២.៣. ក្របខណ្ឌបញ្ញត្តិកម្ម .......................................................................... ៥
២.៤. ការប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម និងការបណ្ដុះបណ្ដាល ....................៧
២.៤.១. ការប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម..........................................៧
២.៤.២. ការបណ្ដុះបណ្ដាល .......................................................................... ៨
២.៥. ស្តង់ដាបច្ចេកទេស .......................................................................... ១០
២.៦. អនុលោមភាព .......................................................................... ១០
២.៦.១. ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាស... ១២
២.៦.២. ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គភាព មិនស្វែងរកប្រាក់ចំណេញ .......................................................................... ១៣
២.៦.៣. ប្រព័ន្ធគ្រប់គ្រងការស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិង សវនកម្មតាមអនឡាញ.......................................................................... ១៣
២.៧. ការត្រួតពិនិត្យគុណភាពសេវាសវនកម្ម .......................................................... ១៣
២.៨. ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាក្នុងវិស័យគណនេយ្យនិងសវនកម្ម...........................១៥
២.៩. អំពីនិយ័តករគណនេយ្យនិងសវនកម្ម.......................................................... ១៥
២.៩.១. ក្របខណ្ឌស្ថាប័ន .......................................................................... ១៥
២.៩.២. ក្របខណ្ឌសហប្រតិបត្តិការ.......................................................................... ១៧

២.១០. ការវិភាគស្ថានភាពបច្ចុប្បន្ន (swot analysis) ..................................... ១៨
២.១០.១. ភាពខ្លាំង (strengths)..................................................... ១៨
២.១០.២. ភាពខ្សោយ (weaknesses) ............................................. ១៨
២.១០.៣. កាលានុវត្តភាព (opportunities) ........................................ ១៩
២.១០.៤. ការគំរាមកំហែង (threats)..................................................២០
២.១១. ចក្ខុវិស័យ គោលបំណង គោលដៅ បេសកកម្ម និងគុណតម្លៃស្ថាប័ន...........២០
២.១១.១. ចក្ខុវិស័យ ....................................................................២០
២.១១.២. គោលបំណង ..................................................................២០
២.១១.៣. គោលដៅ .......................................................................២០
២.១១.៤. បេសកកម្ម .....................................................................២០
២.១១.៥. គុណតម្លៃស្ថាប័ន................................................................២១
**៣. ផែនការយុទ្ធសាស្ត្រ ២០២៥-២០៣៥**..............................................................២២
៣.១. ក្របខណ្ឌបញ្ញត្តិកម្ម ..........................................................................២២
៣.២. ក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្ម ........................២៣
៣.២.១. សសរស្តម្ភទី១៖ ការពង្រឹង និងពង្រីកសមត្ថភាពរបស់ស្ថាប័ន.........២៤
៣.២.២. សសរស្តម្ភទី២៖ ការកសាងមូលធនមនុស្សជំនាញគណនេយ្យនិង សវនកម្មសម្រាប់ទីផ្សារ ..........................................................២៥
៣.២.៣. សសរស្តម្ភទី៣៖ ការដាក់ឱ្យអនុវត្តស្តង់ដាបច្ចេកទេស ..................២៦
៣.២.៤. សសរស្តម្ភទី៤៖ ការលើកកម្ពស់កម្រិតអនុលោមភាព ...................២៧
៣.២.៥. សសរស្តម្ភទី៥៖ ការលើកកម្ពស់គុណភាពសវនកម្ម និងការអះអាង.....២៩
៣.២.៦. សសរស្តម្ភទី៦៖ ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យគណនេយ្យ និងសវនកម្ម ..................................................................៣០
**៤. យន្តការអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តយុទ្ធសាស្ត្រ** .....៣២
**៥. សេចក្តីសន្និដ្ឋាន**.................................................................................. ៣៣
**៦. បរិសិដ្ឋ**..............................................................................................៣៤

# បញ្ជីពាក្យកាត់

| | |
|---|---|
| **ន.គ.ស.** | និយ័តករគណនេយ្យនិងសវនកម្ម |
| **អ.ស.ហ.** | អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ |
| **ក.ជ.គ.** | ក្រុមប្រឹក្សាជាតិគណនេយ្យ |
| **វ.គ.ស.ក.** | វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករជំនាញកម្ពុជា |
| **គ.ក.គ.ក.** | គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា |
| Cam DX | *Cambodia Data Exchange* |
| Cam Digi Key | *Cambodia Digital Key* |
| ADB | *Asia Development Bank* |
| Fintech Centre | *Financial Technology Centre* |
| ACCA | *Association of Certified Chartered Accountant* |
| CPA | *Certified Public Accountant* |
| SMEs | *Small and Medium Size Enterprises* |
| PIEs | *Public Interest Entities* |
| Non-PIEs | *Non-Public Interest Entities* |
| ATQ | *Accounting Technician Qualification* |
| FIN | *Financial Reporting Identification Number* |
| SOP | *Standard Operating Procedure* |
| FDI | *Foreign Direct Investment* |
| IASB | *International Accounting Standards Board* |
| IFAC | *International Federation of Accountants* |
| PCAOB | *Public Company Accounting Oversight Board* |
| AOSSG | *Asian-Oceanian Standard-Setters Group* |
| IPSASB | *International Public Sector Accounting Standard Board* |
| AFA | *ASEAN Federation of Accountants* |
| ACPACC | *ASEAN Chartered Professional Accountant Coordinating Committee* |
| Reg Tech | *Regulatory Technology* |
| Sup Tech | *Supervisory Technology* |

# សេចក្តីសង្ខេបប្រតិបត្តិ

វិស័យគណនេយ្យនិងសវនកម្ម បង្ហាញពីសញ្ញាណចាប់ផ្តើមមានការវិវត្តចាប់ពីឆ្នាំ២០០២ ក្នុងពេលដែលមានវត្តមាននៃច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ។ តាមរយៈច្បាប់នោះ ក្របខណ្ឌវិធានគ្រប់គ្រង ក្របខណ្ឌបច្ចេកទេស និង ក្របខណ្ឌស្ថាប័ន ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់។ ជាមួយគ្នានោះ ធនធានមនុស្សជាគណនេយ្យករ និងសវនករ ចាប់ផ្តើមមានកំណើនគួរឱ្យកត់សម្គាល់ និងដើរទន្ទឹមគ្នាជាមួយកំណើននៃក្រុមហ៊ុន គណនេយ្យនិងសវនកម្ម។ វឌ្ឍនភាពនេះ មានជាបន្តបន្ទាប់ ស្របតាមការវិវត្តនៃវិស័យនេះក្នុងតំបន់ និងពិភពលោក។ រហូតមកដល់ឆ្នាំ២០១៦ វិធានគ្រប់គ្រងត្រូវបានកែសម្រួលនិងធ្វើឱ្យប្រសើរឡើង តាមរយៈការអនុម័តនិងដាក់ឱ្យអនុវត្តច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ដែលត្រូវបានប្រកាសឱ្យ ប្រើដោយព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ជំនួសឱ្យ ច្បាប់ចាស់។ ច្បាប់ស្តីពីគណនេយ្យ និងសវនកម្មឆ្នាំ២០១៦ បានកំណត់នូវវិធានគ្រប់គ្រងវិស័យ គណនេយ្យនិងសវនកម្ម កាន់តែគត់មត់ និងគ្រប់ជ្រុងជ្រោយ តួនាទីស្ថាប័នត្រូវបានពង្រឹង យន្តការ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃត្រូវបានបង្កើតឡើង និងវិធានការពិន័យត្រូវបានកំណត់។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយក៏ភាពខ្វះចន្លោះ និងបញ្ហាប្រឈមនៅតែមាននិងត្រូវអភិវឌ្ឍបន្ថែម។ ក្នុងហេតុផលនេះនិយ័តករគណនេយ្យនិងសវនកម្ម(**ន.គ.ស.**) បានរៀបចំនូវ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា ២០២៥-២០៣៥**" ដោយ កំណត់គោលដៅយុទ្ធសាស្ត្រជាក់លាក់សម្រាប់រយៈពេល ១០ឆ្នាំខាងមុខគឺ "**ប្រព័ន្ធគណនេយ្យ និងសវនកម្មដែលរឹងមាំ មានតម្លាភាព និងអាចជឿទុកចិត្តបាន**"។

ម្យ៉ាងទៀត ដើម្បីសម្រេចឱ្យបាននូវគោលដៅយុទ្ធសាស្ត្រខាងលើ **ន.គ.ស.** បានកំណត់ គោលបំណងរបស់ខ្លួន គឺចង់ឱ្យសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលជាបុគ្គល ជាប់កាតព្វកិច្ចបង្វែរ "**កាតព្វកិច្ចគណនេយ្យនិងសវនកម្មដែលកំណត់ដោយច្បាប់**" ទៅជា "**វប្បធម៌ គណនេយ្យនិងសវនកម្ម**" ដើម្បីដើរទាន់ការរីកចម្រើននៃវិស័យនេះនៅក្នុងបណ្តាប្រទេសជឿនលឿន ក្នុងតំបន់និងពិភពលោក។

ដូច្នេះវិធានការចាំបាច់នានានឹងត្រូវបានដាក់ចេញជាអាទិ៍ ១).ការពង្រឹងសមត្ថភាពស្ថាប័ន, ២).ការអភិវឌ្ឍមូលធនមនុស្សជំនាញគណនេយ្យនិងសវនកម្ម, ៣).ការធ្វើសុខដុមនីយកម្ម ស្តង់ដាបច្ចេកទេស,៤).ការលើកកម្ពស់កម្រិតអនុលោមភាព,៥).ការលើកកម្ពស់គុណភាពសវនកម្ម, និង ៦).ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យគណនេយ្យនិងសវនកម្ម។

លើសពីនេះ សកម្មភាពជាយុទ្ធសាស្ត្រ បានកំណត់ជាក់លាក់ដោយបែងចែកជារយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ដែលចែងក្នុងតារាងបរិសិដ្ឋ។ ដើម្បីជានាប្រសិទ្ធភាពនិងសក្តិសិទ្ធភាពនៃការអនុវត្តវិធានការចាំបាច់នានា នៅក្នុងយុទ្ធសាស្ត្រ គ្រប់តួអង្គពាក់ព័ន្ធត្រូវធ្វើការរួមគ្នាក្នុងស្មារតីសកម្មនិងបុរេសកម្ម ក្នុងក្របខណ្ឌកិច្ចសហការនិងសហប្រតិបត្តិការ។

ដូចគ្នានេះដែរ យន្តការនៃការអនុវត្ត តាមដាន ត្រួតពិនិត្យ និង វាយតម្លៃ ក៏នឹងត្រូវបានបង្កើតឡើងរបបនៃការរាយការណ៍ នឹងត្រូវកំណត់ជាក់លាក់។

ឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្ម គឺជាឯកសាររស់ ដែលនឹងអាចត្រូវបានធ្វើបច្ចុប្បន្នភាព តាមការចាំបាច់។

# ដ្យាក្រាមបង្ហាញពីទំនាក់ទំនងរបស់ភាគីពាក់ព័ន្ធ<br>ក្នុងវិស័យគណនេយ្យនិងសវនកម្ម



# យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្ម នៅកម្ពុជា ២០២៥-២០៣៥

## ១. សេចក្តីផ្តើម

ចាប់ពីចុងទសវត្សរ៍ទី៨០ ប្រទេសកម្ពុជាបានចាប់ផ្តើមប្រកាន់យកសេដ្ឋកិច្ចទីផ្សារសេរីដោយបើកចំហទីផ្សាររបស់ខ្លួន តាមរយៈការផ្លាស់ប្តូរពាណិជ្ជកម្ម និងសេវាកម្មជាមួយបណ្តាប្រទេសនានាលើសកលលោក។ ការបើកចំហទីផ្សារនេះ ធ្វើឱ្យមានលំហូរវិនិយោគឆ្លងទ្វីបដោយគ្មានការកំហិត។ ជាលទ្ធផល សកម្មភាពធ្វើធុរកិច្ច និងការវិនិយោគឯកជន ចាប់ផ្តើមមានកំណើនគួរឱ្យកត់សម្គាល់ពិសេស ក្រោយការបោះឆ្នោតជាសកលឆ្នាំ១៩៩៣។ ការរីកចម្រើននៃវិស័យធុរកិច្ចនិងវិនិយោគឯកជន តម្រូវឱ្យរាជរដ្ឋាភិបាលធ្វើការយកចិត្តទុកដាក់លើការកែទម្រង់លើវិស័យពាក់ព័ន្ធមួយចំនួនដើម្បីគាំទ្រដល់វិស័យឯកជន និងអាចគ្រប់គ្រងបាន។ ការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលបានចាប់ផ្តើមពីកម្មវិធីកំណែទម្រង់រដ្ឋដែលក្នុងនោះមានកំណែទម្រង់វិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយត្រូវបានរាជរដ្ឋាភិបាលបានចាត់ទុកជាឆ្អឹងខ្នងនៃការទ្រទ្រង់ចីរភាពនៃកំណើន តាមរយៈការបង្កើតនូវក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិ និងក្របខណ្ឌស្ថាប័នសម្រាប់គ្រប់គ្រង ដើម្បីបង្កើតនូវប្រព័ន្ធគណនេយ្យហិរញ្ញវត្ថុដ៏រឹងមាំដែលធានាបាននូវតម្លាភាព និងភាពអាចជឿទុកចិត្តបាន សម្រាប់គាំទ្រដល់សកម្មភាពវិនិយោគ និងការធ្វើធុរកិច្ច។

របាយការណ៍ហិរញ្ញវត្ថុអនុលោមតាមស្តង់ដាគណនេយ្យ ដែលទទួលបានការធ្វើសវនកម្មឯករាជ្យប្រកបដោយគុណភាព គឺជាមូលដ្ឋានចាំបាច់មិនអាចខ្វះបានក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ច សម្រាប់ភាគីពាក់ព័ន្ធ។ ផ្អែកលើមូលដ្ឋាននេះ ស្តង់ដាគណនេយ្យ និងស្តង់ដាសវនកម្មដែលជាឧបករណ៍គណនេយ្យ និងសវនកម្មដែលមានលក្ខណៈស្របតាមបរិបទអន្តរជាតិត្រូវបានដាក់ឱ្យអនុវត្តជាបន្តបន្ទាប់តាមដំណាក់កាល។ ជាមួយនឹងភាពចាំបាច់នេះ ការបង្កើតក្រុមហ៊ុនគណនេយ្យ និងសវនកម្ម គឺជាយន្តការមួយដើម្បីបំពេញតម្រូវការរបស់វិនិយោគិននិងធុរជនលើការបញ្ជាក់អំពីតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើកិច្ចបញ្ជិកាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ហើយតួនាទីវិស័យគណនេយ្យនិងសវនកម្មត្រូវបានដាក់បញ្ចូលក្នុងឯកសារ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥**" ដែលជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នភាពរៀងរាល់៥ឆ្នាំម្តង។

ផ្អែកលើមូលដ្ឋានច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ មានស្ថាប័នចំនួនពីរត្រូវបានបង្កើតឡើង គឺក្រុមប្រឹក្សាជាតិគណនេយ្យ (**ក.ជ.គ.**) ដែលជាស្ថាប័នកំណត់ស្តង់ដា (Standard- Setting Body) និងវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ដែលជាស្ថាប័នវិជ្ជាជីវៈ (Professional- Body)។ ផ្តើមចេញពីច្បាប់នេះ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានមួយចំនួនត្រូវបានដាក់ឱ្យអនុវត្តជាបណ្តើរៗ។ នាឆ្នាំ២០០៩ កម្ពុជាបានដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ និងស្តង់ដាសវនកម្ម យ៉ាងពេញលេញ ដោយអនុម័តយកស្តង់ដាគណនេយ្យអន្តរជាតិទាំងស្រុងមកអនុវត្ត។ ជាមួយគ្នានេះ ក្រុមហ៊ុនផ្តល់សេវាគណនេយ្យ និងសវនកម្ម ចាប់ផ្តើមបង្កើតនិងមានចំនួនច្រើនឡើង ដោយផ្តើមចេញពីចំនួន ១ ក្រុមហ៊ុន នាឆ្នាំ២០០៤ និងបន្តកើនឡើងជារៀងរហូត ដល់ចុងឆ្នាំ២០២៤ នេះ ក្រុមហ៊ុនគណនេយ្យ និងសវនកម្ម មានចំនួនរហូតដល់ទៅ ៩៩ ក្រុមហ៊ុន។

**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្ម នៅកម្ពុជា ២០២៥-២០៣៥** នេះត្រូវបានរៀបចំឡើងក្នុងគោលបំណងគិតគូរលើការជំរុញការអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្ម ក្នុងកាលៈទេសៈដែលពិភពលោក ក៏ដូចជាកម្ពុជា កំពុងប្រឈមនឹងការលំបាកផ្នែកសេដ្ឋកិច្ច ដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ និងជម្លោះរវាងប្រទេសរុស្សីនិងអ៊ុយក្រែន ដែលការណ៍នេះ កំពុងតែជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់កំណើនសេដ្ឋកិច្ចនិងសុខមាលភាពសង្គម។ យុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋានជាក់ស្តែង ប្រាកដនិយម ការប្រកបវិជ្ជាជីវៈនៅកម្ពុជា ការវាយតម្លៃរបស់ដៃគូអភិវឌ្ឍន៍តាមរយៈរបាយការណ៍ស្តីពីការគោរពតាមស្តង់ដា និងក្រមច្បាប់នានា (Report on Observance Standards and Codes-ROSC) ជាតុចូលពីវិស័យឯកជន និងស្ថាប័នពាក់ព័ន្ធ និងការសិក្សាដកបទពិសោធន៍ពីបណ្តាប្រទេសក្នុងតំបន់ និងឧត្តមានុវត្តន៍ជាអន្តរជាតិ។

## ២. ស្ថានភាពបច្ចុប្បន្ន

### ២.១. ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

ក្រោមម្លប់នៃសុខសន្តិភាព និងស្ថិរភាពនយោបាយក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមក ដែលជាសមិទ្ធផលមិនអាចកាត់ថ្លៃបាន នាំមកជូនប្រជាជនកម្ពុជា ដោយ **សម្តេចអគ្គមហា-សេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងទោះស្ថិតក្នុងបរិការណ៍នៃការរីករាលដាលនៃវិបត្តិកូវីដ-១៩ រាជរដ្ឋាភិបាលបានរៀបចំ និងដាក់ឱ្យអនុវត្តនូវគោលនយោបាយ និងវិធានការជាបន្តបន្ទាប់លើផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច ដើម្បីពង្រឹងការអភិវឌ្ឍ

វិស័យឯកជននិងសាធារណៈ តាមរយៈការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច សម្រាប់ការទាក់ទាញការវិនិយោគពីបរទេស និងជំរុញពាណិជ្ជកម្ម សំដៅពន្លឿនការធ្វើពិពិធកម្មសេដ្ឋកិច្ច ពង្រឹងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន។

ឆ្នាំ២០២៣ និងឆ្នាំ២០២៤ គឺជាដំណាក់កាលដែលកម្ពុជាបន្តការងារស្តារសង្គម-សេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ និងត្រូវបោះជំហានលើមាគ៌ានៃគន្លងអភិវឌ្ឍន៍ថ្មី បន្ទាប់ពីរងការប៉ះទង្គិចយ៉ាងខ្លាំងពីវិបត្តិជំងឺកូវីដ-១៩ ខណៈដែលអាណត្តិរបស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភាបានបញ្ចប់។ ក្នុងរយៈពេលជាងពីរឆ្នាំកន្លងមក រាជរដ្ឋាភិបាលកម្ពុជាមិនបានបង្អង់កិច្ចខិតខំប្រឹងប្រែងក្នុងការជំរុញការអនុវត្តការងារកែទម្រង់សំខាន់ៗ ជាពិសេស ការអនុវត្ត និងសម្រេចឱ្យបាននូវគោលដៅយុទ្ធសាស្ត្រ ដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ សំដៅជំរុញកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព និងបរិយាប័ន្ន។

ផ្អែកលើស្ថានភាពបច្ចុប្បន្ន សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២៤ ត្រូវបានវាយតម្លៃថាបន្តសម្រេចបាននូវអត្រាកំណើន ៦,០% ដូចការគ្រោងទុក ដោយការងើបឡើងវិញលឿននៃវិស័យកាត់ដេរ, ការបន្តកើនឡើងនៃវិស័យទេសចរណ៍និងវិស័យកសិកម្ម, និងកំណើននៃវិស័យដឹកជញ្ជូននិងស្តុក នៅពេលដែលវិស័យសំណង់និងអចលនទ្រព្យនៅបន្តមានកំណើនទាប។

ដូចគ្នានេះដែរ ទាំងការនាំចេញ ពិសេសវិស័យកាត់ដេរ និងទាំងការនាំចូល ពិសេសសម្ភារៈគាំទ្រវិស័យកាត់ដេរ និងសម្ភារៈសំណង់ មានកំណើនខ្ពស់ក្នុងរយៈពេល៣ត្រីមាស ដើមឆ្នាំ២០២៤។

សម្រាប់វិស័យហិរញ្ញវត្ថុ ពិសេសធនាគារ ការផ្តល់ឥណទានដោយគ្រឹះស្ថានហិរញ្ញវត្ថុ មានកំណើនយឺត ជាមួយគ្នានឹងការកើនឡើងនៃប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ និងមីក្រូហិរញ្ញវត្ថុ។

ទស្សនវិស័យសេដ្ឋកិច្ចរបស់កម្ពុជាត្រូវបានហ៊ុំព័ទ្ធដោយហានិភ័យគួរឱ្យកត់សម្គាល់ និងបញ្ហារចនាសម្ព័ន្ធដែលនៅសេសសល់ ខណៈឱកាសនៅតែមានភាពរឹងមាំ ក្នុងនោះបញ្ហាប្រឈមខាងក្រៅមានដូចជា៖ ការធ្លាក់ចុះសេដ្ឋកិច្ចសកលនិងចិន ការរឹតបន្តឹងជាសកលនៃគោលនយោបាយរូបិយវត្ថុ ការកើនឡើងនៃការការពារនិយម និងការបែកបាក់ភូមិសាស្ត្រសេដ្ឋកិច្ច ការប្រែប្រួលអាកាសធាតុ ការឡើងកំដៅភពផែនដី។ បញ្ហាប្រឈមខាងក្នុងមានដូចជា៖ តម្លៃនៃការធ្វើអាជីវកម្មខ្ពស់ និងការប្រកួតប្រជែងទាប ពលកម្មមានកម្រិតនិងជំនាញទាប ការទទួលយកនិងការផ្លាស់ប្តូរឌីជីថលទាប ប្រព័ន្ធថែទាំសុខភាពនិងការការពារសង្គមមានកម្រិត។ កាលានុវត្តភាពមានដូចជា៖ ការរុះរើនិងផ្លាស់ប្តូរទីតាំងនៃខ្សែសង្វាក់ផ្គត់ផ្គង់ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (CCFTA, CKFTA, និង RCEP) និងការពន្លឿនកំណែទម្រង់រចនាសម្ព័ន្ធសំខាន់ៗ។

ទិសដៅគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ទិសដៅយុទ្ធសាស្ត្រ នឹងផ្តោតលើអាទិភាពសំខាន់ៗចំនួនប្រាំមួយមានដូចជាៈ ១).ការអភិវឌ្ឍធនធានមនុស្ស, ២).ការពង្រឹងពិពិធកម្មសេដ្ឋកិច្ចនិងភាពប្រកួតប្រជែង, ៣).ការអភិវឌ្ឍវិស័យឯកជននិងការងារ, ៤).ការអភិវឌ្ឍប្រកបដោយភាពធន់ចីរភាពនិងបរិយាប័ន្ន,៥).ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល និង, ៦).ការពង្រឹងរដ្ឋបាលសាធារណៈ។ បន្ថែមពីលើនេះ ក៏បានកំណត់អាទិភាពសំខាន់ៗចំនួនប្រាំមួយបន្ថែមទៀតមានដូចជា៖១).ការផ្តល់សេវាថែទាំសុខភាព,២).ការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេស, ៣).ការរៀបចំកម្មវិធីជំនួយសង្គមជាតិ, ៤).ការអនុម័តនិងជំរុញយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធ, ៥).ជំរុញយន្តការសម្របសម្រួលនិងកម្មវិធីហិរញ្ញប្បទាន និង, ៦).ការដាក់ពង្រាយមន្ត្រីកសិកម្ម។

ម្យ៉ាងទៀត ការបង្កើត និងការធ្វើឱ្យបរិយាកាសធុរកិច្ច និងវិនិយោគមានភាពប្រសើរតាមរយៈការលើកកម្ពស់អនុលោមភាពគណនេយ្យនិងសវនកម្ម គឺជាកត្តាកំណត់មួយក្នុងចំណោមកត្តាកំណត់ផ្សេងទៀត ដើម្បីជំរុញ និងទ្រទ្រង់កំណើនសេដ្ឋកិច្ច និងធានាបាននូវចីរភាពនៃកំណើនអនុលោមភាពនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ២.២. ក្របខណ្ឌគោលនយោបាយវិស័យគណនេយ្យនិងសវនកម្ម

ផ្អែកលើយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដែលត្រូវបានរាជរដ្ឋាភិបាលដាក់ឱ្យអនុវត្តនៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ សម្រាប់នីតិកាលទី៧នៃរដ្ឋសភា ការអភិវឌ្ឍនិងការគ្រប់គ្រងវិស័យគណនេយ្យនិងសវនកម្មឱ្យបានល្អប្រសើរ គឺជាការងារចាំបាច់ដើម្បីទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ច តាមរយៈការបង្កើតបរិយាកាសវិនិយោគឱ្យកាន់តែប្រសើរ ការលើកកម្ពស់អភិបាលកិច្ចល្អសម្រាប់វិស័យឯកជន សំដៅសម្រេចឱ្យបាននូវអាទិភាពគន្លឹះទាំង៥របស់រាជរដ្ឋាភិបាលកម្ពុជា រួមមាន មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា ដែលបានកំណត់ក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដោយត្រូវបានធ្វើបច្ចុប្បន្នភាពបន្ថែមលើយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំង៤ដំណាក់កាល។

លើសពីនេះ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥ បានបញ្ជាក់ពីសារៈសំខាន់នៃការកាន់កិច្ចបញ្ជិកាគណនេយ្យ និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន ហើយរំលេចពីឧបសគ្គ បញ្ហាប្រឈម និងភាពខ្វះខាត ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ដោះស្រាយ ជាពិសេស លើការធ្វើអនុលោមភាពទៅនឹងស្តង់ដាគណនេយ្យនិងការកសាងសមត្ថភាពគណនេយ្យករ សម្រាប់ទីផ្សារ។

យ៉ាងណាមិញ ដើម្បីសម្រេចនូវគោលបំណងនៃរដ្ឋាភិបាលឌីជីថល និងសេដ្ឋកិច្ចឌីជីថល បរិវត្តកម្មឌីជីថល ក្នុងវិស័យគណនេយ្យនិងសវនកម្មនឹងត្រូវយកចិត្តទុកដាក់ក្នុងក្របខណ្ឌនៃការអនុវត្តគោលនយោបាយបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

ដោយឡែក សម្រាប់វិស័យសាធារណៈ តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា២០២១-២០៣១បានបង្ហាញពីដំណាក់កាលទាំង៤ សម្រាប់ការឈានទៅការអនុវត្តគណនេយ្យមូលដ្ឋានបង្គរ ដោយចាប់ផ្តើមពីដំណាក់កាលទី១៖ គណនេយ្យមូលដ្ឋានសាច់ប្រាក់ (២០១៩-២០២៤) ដំណាក់កាលទី២៖ គណនេយ្យមូលដ្ឋានសាច់ប្រាក់កែសម្រួល (២០២៥-២០២៧) ដំណាក់កាលទី៣៖ គណនេយ្យមូលដ្ឋានបង្គរកែសម្រួល (២០២៨-២០៣០) និងដំណាក់កាលទី៤៖ គណនេយ្យមូលដ្ឋានបង្គរ ចាប់ពីឆ្នាំ២០៣១ តទៅ។

## ២.៣. ក្របខណ្ឌបញ្ញត្តិកម្ម

ចាប់ពីឆ្នាំ២០០២ ច្បាប់និងលិខិតបទដ្ឋានសម្រាប់ការគ្រប់គ្រងវិស័យគណនេយ្យនិងសវនកម្ម ដែលត្រូវបានដាក់ឱ្យអនុវត្ត និងនៅមានសុពលភាពអនុវត្ត មានដូចខាងក្រោម៖

- ព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- ព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- អនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
- អនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី ១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- អនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ប្រកាសលេខ ០៦៨ សហវ.ប្រក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុនៃកម្ពុជា
- ប្រកាសលេខ ៣៧០ សហវ.ប្រក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ ស្តីពីការដាក់ឱ្យប្រើស្តង់ដាទាក់ទងនឹងសវនកម្ម និងស្តង់ដាការអះអាងអន្តរជាតិនៃកម្ពុជា

- ប្រកាសលេខ ១០១ សហវ.ប្រក ចុះថ្ងៃ២៤ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ប្រកាសលេខ ៣៣៥ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ
- ប្រកាសលេខ ៥៤៥ សហវ.ប្រកចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់
- ប្រកាសលេខ ១០៣ សហវ.ប្រក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ស្តីពីការអនុញ្ញាតឱ្យគណនេយ្យករជំនាញ និងសវនកប្រតិស្រុតជាជនបរទេសមានសិទ្ធិបន្តចុះហត្ថលេខាលើរបាយការណ៍គណនេយ្យ និងរបាយការណ៍សវនកម្ម
- ប្រកាសលេខ ៥៦៣ សហវ.ប្រក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ
- ប្រកាសលេខ ៧៧៩ សហវ.ប្រក ចុះថ្ងៃ១២ ខែតុលា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យអនុវត្តក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គណនេយ្យករជំនាញនិងសវនករប្រតិស្រុតកម្ពុជា
- ប្រកាសលេខ ០១៣ អ.ស.ហ.ប្រក ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២២ ស្តីពីការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- ប្រកាសលេខ ០១៩ អ.ស.ហ.ប្រក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
- ប្រកាសលេខ ០១១ អ.ស.ហ. ប្រកចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤ ស្តីពីការស្នើសុំប្រើប្រាស់ការិយបរិច្ឆេទគណនេយ្យពិសេស
- សេចក្តីសម្រេចលេខ ០១១ ន.គ.ស.គ.ក.គ.ក. ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ពិសេសសម្រាប់កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា
- សារាចរណែនាំលេខ ០២២/២៣ ន.គ.ស./ស.រ.ណ.ន. ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីក្នុងការទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្មសម្រាប់គណនេយ្យករនិងសវនករជាជនបរទេស
- សារាចរណែនាំលេខ០០៩ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីការប្រើប្រាស់ភាសា និងរូបិយប័ណ្ណក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ
- សារាចរណែនាំលេខ០០៤ ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០១៩ ស្តីពីការអនុវត្តសេចក្តីជូនដំណឹងស្តីពីការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ។

## ២.៤. ការប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម និងការបណ្តុះបណ្តាល

### ២.៤.១. ការប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម

#### ២.៤.១.១. ក្រុមហ៊ុនប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម

គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤ ក្រុមហ៊ុនដែលទទួលបាននីតិសម្បទាផ្តល់សេវាគណនេយ្យ និងសវនកម្ម ពី **ន.គ.ស.** មានចំនួន៩៨ ក្រុមហ៊ុន ដែលក្នុងនោះមានក្រុមហ៊ុនប្រកបវិជ្ជាជីវៈគណនេយ្យកម្រិត១ ចំនួន៨ក្រុមហ៊ុន និងកម្រិត២ ចំនួន៣៦ ក្រុមហ៊ុន និងក្រុមហ៊ុនប្រកបវិជ្ជាជីវៈសវនកម្មចំនួន៥៤ ក្រុមហ៊ុន ដែលក្នុងនោះសវនករជាជនជាតិខ្មែរ មានចំនួន ៦៤រូប និងជនបរទេសមានចំនួន ៣៨ រូប។ តាមរយៈការជំរុញការអនុវត្តកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ ចំនួនក្រុមហ៊ុនសវនកម្ម ត្រូវបានមើលឃើញថានៅមានចំនួនតិចនៅឡើយបើធៀបនឹងតម្រូវការទីផ្សារ ដូច្នេះការបន្តអនុញ្ញាតឱ្យជនបរទេសមានសិទ្ធិចុះហត្ថលេខាលើរបាយការណ៍សវនកម្មនៅកម្ពុជា គឺជាយន្តការចាំបាច់និងមានលក្ខណៈបណ្តោះអាសន្នសម្រាប់រយៈពេលខ្លីដើម្បីធានាគុណភាព សេវាសវនកម្ម និងកាត់បន្ថយចំណាយរបស់សហគ្រាស។







#### ២.៤.១.២. សមាជិករបស់វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា

គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៤ សមាជិកជារូបវន្តបុគ្គលដែលបានចុះឈ្មោះនៅវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា (**វ.គ.ស.ក.**) ដោយរាប់បញ្ចូលទាំងជនបរទេសមានចំនួន ១៣២៦ រូប ដែលក្នុងនោះសមាជិកសកម្មជាគណនេយ្យករមានចំនួន ២៤ រូប (ជនបរទេស៩ រូប) សមាជិកសកម្ម ជាសវនករមានចំនួន ១៧៧ រូប (ជនបរទេស៨៣ រូប) សមាជិកសមាគត់មានចំនួន ២៦ រូប (បរទេស២ រូប) សមាជិកចូលរួមមានចំនួន ២០៨ រូប (ជនបរទេសមាន១៧ រូប) និងសមាជិកជានិស្សិតឬបម្រុងមានចំនួន ៨៩៤ រូប។







## ២.៤.២. ការបណ្តុះបណ្តាល

### ២.៤.២.១. ការបណ្តុះបណ្តាលគណនេយ្យករជំនាញតាមរយៈអាហារូបករណ៍របស់រដ្ឋ

ក្រោមគម្រោងដែលផ្តល់ហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់អាហារូបករណ៍ដល់និស្សិតចំនួន ៨៧៥នាក់ ហើយគិតត្រឹមខែមីនា ឆ្នាំ២០១៩ និស្សិតបានបញ្ចប់កម្មវិធីសិក្សាគណនេយ្យករជំនាញ (ACCA/CAT) ដោយជោគជ័យមានចំនួនតែ ៨៥នាក់ ប៉ុណ្ណោះ ដែលទាបជាងផែនការដែលបានដាក់ចេញចំនួន១៥០នាក់។ ទោះបីជាយ៉ាងនេះក្តី មន្ត្រីរាជការ និងនិស្សិត កម្ពុជា បានចូលរៀនកម្មវិធីនេះដោយទទួលបានចំណេះដឹងបច្ចេកទេសគណនេយ្យនិងសវនកម្មច្រើនគួរជាទីមោទនភាព។

### ២.៤.២.២. ការបណ្តុះបណ្តាលដោយវិស័យឯកជន

ក្រៅពីកម្មវិធីអាហារូបករណ៍ដែលផ្តល់ដោយរាជរដ្ឋាភិបាល ប្រជាពលរដ្ឋខ្មែរបានបង់ថ្លៃសិក្សាដោយខ្លួនឯងដើម្បីបានចូលរួមការបណ្តុះបណ្តាលកម្មវិធីសិក្សាគណនេយ្យករជំនាញ (ACCA) របស់ចក្រភពអង់គ្លេស និងកម្មវិធីសិក្សាគណនេយ្យករជំនាញរបស់ប្រទេសអូស្ត្រាលី (CPA Australia) ដែលកម្មវិធីអន្តរជាតិទាំងពីរទទួលបានការចុះអនុស្សរណៈយោគយល់គ្នាជាមួយ **វ.គ.ស.ក.**។ លទ្ធផលដែលទទួលបានពីការបណ្តុះបណ្តាលកម្មវិធីទាំងនេះ ចំនួននៅមានកម្រិតតិចតួចនៅឡើយ ដោយផ្អែកតាមទិន្នន័យដែលបានផ្តល់ដោយការិយាល័យតំណាងរបស់សមាគមគណនេយ្យករជំនាញ (ACCA) ប្រចាំប្រទេសកម្ពុជា គិតត្រឹម ឆ្នាំ២០២៤ គឺប្រមាណ ៣៣៧នាក់ ជាជនជាតិខ្មែរ បានបញ្ចប់ ១៣ មុខវិជ្ជានៃកម្មវិធីនេះ។

### ២.៤.២.៣. កម្មវិធីសិក្សា

**ក.កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា**

កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការ ដោយប្រកាសលេខ ៣១៨ សហវ.ប្រក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យអនុវត្តកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា។ កម្មវិធីសិក្សានេះ ស្ថិតក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា (**គ.ក.គ.ក.**) ដែលបានបង្កើតឡើងតាមរយៈប្រកាសលេខ១៣២ សហវ.ប្រក ចុះថ្ងៃទី១២ ខែកុម្ភៈឆ្នាំ២០២០ ស្តីពីការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា។

ផ្អែកលើភាពចាំបាច់នៃការកែសម្រួលរចនាសម្ព័ន្ធស្ថាប័ន ការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ត្រូវបានរៀបចំឡើងជាថ្មីតាមរយៈប្រកាសលេខ០១៣ អ.ស.ហ.ប្រក ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២២ស្តីពីការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា របស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

**ខ.ការដាក់ឱ្យអនុវត្តគោលការណ៍ពិសេសសម្រាប់កម្មវិធីគណនេយ្យករជំនាញកម្ពុជា**

ក្នុងទិសដៅបង្កើនធនធានមនុស្សក្នុងវិស័យគណនេយ្យនិងសវនកម្មឱ្យបានច្រើនក្នុងល្បឿនលឿនជាមួយនឹងគុណភាពអាចទទួលយកបាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ចេញគោលការណ៍ពិសេសសម្រាប់កម្មវិធីគណនេយ្យករជំនាញកម្ពុជា នាថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២១ និងបានអនុវត្តជាផ្លូវការកាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១។ គោលបំណងនៃការដាក់ឱ្យអនុវត្តគោលការណ៍ពិសេស ដើម្បីបង្កើតច្រករហ័សសម្រាប់អ្នកសិក្សាទាំងឡាយដែលអាចបំពេញលក្ខខណ្ឌដែលកំណត់ក្នុងគោលការណ៍ពិសេសបាន ដើម្បីទទួលបានការទទួលស្គាល់ពី **គ.ក.គ.ក.** ជាគណនេយ្យករជំនាញកម្ពុជា ដោយពុំចាំបាច់ឆ្លងកាត់ការសិក្សាតាមកម្មវិធីផ្លូវការនៃកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជានោះទេ។

**គ.កម្មវិធីសិក្សាអ្នកបច្ចេកទេសគណនេយ្យ** (Accounting Technician Qualification - ATQ)

កម្មវិធីសិក្សាអ្នកបច្ចេកទេសគណនេយ្យ (ATQ) ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ ក្រោមជំនួយឧបត្ថម្ភពី UNDP ដោយមានជំនួយបច្ចេកទេសពី ICAEW ដែលមានរយៈពេល៣ឆ្នាំ (២០២០-២០២៣) និងស្ថិតក្រោមការគ្រប់គ្រងរបស់ **ឋ.គ.ស.ក.**។ កម្មវិធីសិក្សាអ្នកបច្ចេកទេសគណនេយ្យនេះ ចែកចេញជា ៤ផ្នែក រួមមាន ៨មុខវិជ្ជា។ **ឋ.គ.ស.ក.** ជាស្ថាប័ននាំមុខក្នុងការជំរុញការអនុវត្តកម្មវិធីនេះជាមួយគ្រឹះស្ថានសិក្សានានានៅទូទាំងប្រទេស។

ក្រោយការបញ្ចប់ការសិក្សាបានជោគជ័យ សិស្ស និស្សិត អាចរកការងារបានធ្វើជាអ្នកកត់ត្រាបញ្ជី និងគណនេយ្យករដែលមានគុណវុឌ្ឍិសមល្មមសម្រាប់ជួយសហគ្រាស និងអង្គភាពសេដ្ឋកិច្ចផ្សេងៗ។

## ២.៥. ស្តង់ដាបច្ចេកទេស

ស្តង់ដាបច្ចេកទេសដែលរួមមានស្តង់ដាគណនេយ្យនិងស្តង់ដាសវនកម្មគឺជាឧបករណ៍ដែលកំណត់ពីគោលការណ៍ វិធាន ការណែនាំចាំបាច់នានា សម្រាប់គណនេយ្យករ និងសវនករ ដើម្បីអនុវត្តតាម។ ចាប់ពីឆ្នាំ២០០៩មក ស្តង់ដាគណនេយ្យនិងស្តង់ដាសវនកម្មត្រូវបានដាក់ឱ្យអនុវត្ត និងកែសម្រួលជាបន្តបន្ទាប់ ហើយដំណាក់កាលចុងក្រោយនេះ មានស្តង់ដានិងគោលការណ៍ណែនាំដែលត្រូវបានដាក់ឱ្យអនុវត្តរួមមាន៖ ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា, ស្តង់ដាទាក់ទងនឹងសវនកម្ម និងស្តង់ដាការអះអាងអន្តរជាតិនៃកម្ពុជា, ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ, ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញកម្រិត១, ស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់, គោលការណ៍ណែនាំស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានសាច់ប្រាក់សម្រាប់គម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងស្តង់ដាគណនេយ្យសាធារណៈកម្ពុជាលេខ៩ ស្តីពីចំណូលពីប្រតិបត្តិការដោះដូរ និងលេខ២៣ ចំណូលពីប្រតិបត្តិការមិនដោះដូរ។

## ២.៦. អនុលោមភាព

ច្បាប់ស្តីពីគណនេយ្យ និងសវនកម្មឆ្នាំ២០១៦ បានកំណត់កាតព្វកិច្ចជាសារវន្តសម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ គឺ កាតព្វកិច្ចកាន់បញ្ជីគណនេយ្យ, កាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាជាធរមាន និងកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ។ ដើម្បីពង្រឹងការអនុវត្តកាតព្វកិច្ចទាំងនេះ និងដើម្បីលើកកម្ពស់កម្រិតអនុលោមភាព ទណ្ឌកម្មមួយចំនួនត្រូវបានកំណត់ទាំងនៅក្នុងច្បាប់ស្តីពីគណនេយ្យ និងសវនកម្មឆ្នាំ២០១៦ និងក្នុងអនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ឆ្នាំ២០២០។ ទោះបីជាយ៉ាងណាក៏ដោយ អនុក្រឹត្យនេះ ត្រូវបានពន្យារពេលអនុវត្តរយៈពេលមួយឆ្នាំរហូតដល់ឆ្នាំ២០២១។ ការពង្រឹងអនុលោមភាពបានចាប់ផ្តើមពីការពិនិត្យលើអនុលោមភាពគតិយុត្តិ (Legal Compliance) ដោយយករបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២០ជាមូលដ្ឋាន និងផ្តោតលើការកាន់បញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងការដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យស្របតាមលក្ខខណ្ឌដែលបានកំណត់ និងបន្តពង្រឹងអនុលោមភាពបច្ចេកទេស (Technical Compliance) ជាបន្តបន្ទាប់តាមស្ថានភាពជាក់ស្តែង។

ដូចគ្នានេះដែរ ក្នុងបរិការណ៍សេដ្ឋកិច្ចឌីជីថល **ន.គ.ស.** បានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ACAR E-Filing System) ដើម្បីទទួលនិងតម្កល់របាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសចាប់ពីការិយបរិច្ឆេទគណនេយ្យ២០២០ និងអង្គភាពមិនស្វែងរកប្រាក់ចំណេញចាប់ពីឆ្នាំ២០២១។

លទ្ធផលនៃការដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** បានបង្ហាញថា សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញមួយចំនួនបានចូលរួមអនុវត្តកាតព្វកិច្ច និងសហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញមួយចំនួនទៀតមិនទាន់បានចូលរួមបំពេញកាតព្វកិច្ចនៅឡើយ។

ខាងក្រោមនេះជាតារាងស្ថិតិសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលបានដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.**៖

| ឆ្នាំ | សហគ្រាស | | អង្គភាពមិនស្វែងរកប្រាក់ចំណេញ | |
|---|---|---|---|---|
| | រងសវនកម្មឯករាជ្យ | មិនរងសវនកម្មឯករាជ្យ | រងសវនកម្មឯករាជ្យ | មិនរងសវនកម្មឯករាជ្យ |
| ២០២១ | ៨៥៦ | មិនទាន់អនុវត្ត | មិនទាន់អនុវត្ត | មិនទាន់អនុវត្ត |
| ២០២២ | ១ ៦៥០ | ១០ ៨៩៤ | ១៦៣ | ៣៧៩ |
| ២០២៣ | ១ ៩៨០ | ១២ ៧៧៦ | ១៩១ | ៤៩៩ |
| ២០២៤ | ២ ៣២៨ | ១៤ ៤១១ | ១៩០ | ៥៦០ |







**ន.គ.ស.** បានចាប់ផ្តើមចុះត្រួតពិនិត្យការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម ដោយយកការិយបរិច្ឆេទគណនេយ្យ ២០២០ ជាគោល។

ខាងក្រោមនេះជាតារាងស្ថិតិសហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលបានចុះត្រួតពិនិត្យកាតព្វកិច្ចគណនេយ្យនិងសវនកម្ម៖

| ឆ្នាំ | ចំនួនសហគ្រាសបានចុះត្រួតពិនិត្យ | ប្រភេទសហគ្រាស | | |
|---|---|---|---|---|
| | | ជាប់ពន្ធធំ | ជាប់ពន្ធធំ (QIP) | ជាប់ពន្ធមធ្យម |
| ២០២១ | ១៩ | ៧ | ៥ | ៧ |
| ២០២២ | ៩៨ | ១៣ | ៦៣ | ២២ |
| ២០២៣ | ៥២ | ៤ | ៣៤ | ១៤ |

| ឆ្នាំ | ចំនួនអង្គភាពបានចុះត្រួតពិនិត្យ | ប្រភេទអង្គភាព | |
|---|---|---|---|
| | | អង្គភាព | សមាគម |
| ២០២១ | មិនទាន់អនុវត្ត | មិនទាន់អនុវត្ត | មិនទាន់អនុវត្ត |
| ២០២២ | មិនទាន់អនុវត្ត | មិនទាន់អនុវត្ត | មិនទាន់អនុវត្ត |
| ២០២៣ | ១០ | ៤ | ៦ |







## ២.៦.១. ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាស

ក្នុងខែកក្កដា ឆ្នាំ២០២១ **ន.គ.ស**. បានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសជំនាន់ទី១។ ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសជំនាន់ទី១ នេះ ត្រូវបានដាក់ឱ្យប្រើប្រាស់សម្រាប់សហគ្រាសរងសវនកម្មឯករាជ្យដែលមានមុខងារសំខាន់ៗពីរគឺ៖ ទី១.មុខងារស្នើសុំលេខអត្តសញ្ញាណកម្មរបាយការណ៍ហិរញ្ញវត្ថុ និងទី២.មុខងារដាក់របាយការណ៍ហិរញ្ញវត្ថុ។

ក្នុងខែកុម្ភៈ ឆ្នាំ២០២២ **ន.គ.ស.** បានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសជំនាន់ទី២។ ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសជំនាន់ទី២ នេះ ត្រូវបានដាក់ឱ្យប្រើប្រាស់ទាំងសហគ្រាសរងសវនកម្មឯករាជ្យ និងសហគ្រាសដែលមិនរងសវនកម្មឯករាជ្យ ដោយបានធ្វើបច្ចុប្បន្នភាពលើមុខងារដែលមានស្រាប់ និងបានបន្ថែមមុខងារថ្មីមួយទៀតគឺ មុខងារជូនដំណឹងអំពីការប្រើប្រាស់ភាសានៅក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ និងប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធផ្សេងៗ។

### ២.៦.២. ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

ក្នុងឆ្នាំ ២០១៨ ក្រុមប្រឹក្សាជាតិគណនេយ្យ (បច្ចុប្បន្ន **ន.គ.ស.**) បានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការស្នើសុំលេខអត្តសញ្ញាណកម្មរបាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ តាមប្រព័ន្ធអនឡាញ ដែលមានមុខងារស្នើសុំលេខអត្តសញ្ញាណកម្មរបាយការណ៍ហិរញ្ញវត្ថុ បានធ្វើទំនើបកម្ម នាខែមិថុនា ឆ្នាំ២០២២។ ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុ សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញជំនាន់ទី១នេះ មានមុខងារសំខាន់ៗបី គឺ៖ ទី១.មុខងារស្នើសុំលេខអត្តសញ្ញាណកម្មរបាយការណ៍ហិរញ្ញវត្ថុ ទី២.មុខងារដាក់របាយការណ៍ហិរញ្ញវត្ថុ និងទី៣.មុខងារជូនដំណឹងអំពីការប្រើប្រាស់ភាសានៅក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ និងប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធផ្សេងៗ។

### ២.៦.៣.ប្រព័ន្ធគ្រប់គ្រងការស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្មតាមអនឡាញ

ក្នុងក្របខណ្ឌចូលរួមអនុវត្តគោលនយោបាយស្ដីពី "**ការរៀបចំការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដំណាក់កាលទី៣**" **ន.គ.ស.** បានដាក់បញ្ចូលសេវាសាធារណៈស្ដីពី "**ការផ្ដល់ និងការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្មតាមប្រព័ន្ធអនឡាញ**" ក្នុងប្រព័ន្ធថ្នាលផ្លាស់ប្ដូរទិន្នន័យកម្ពុជា CamDx។ បច្ចុប្បន្ន **ន.គ.ស.** កំពុងរៀបចំអភិវឌ្ឍប្រព័ន្ធនៃការផ្ដល់និងការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម តាមអនឡាញ ដែលមានមុខងារសំខាន់ៗចំនួនប្រាំមួយដែលបានដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ២០២៣។

## ២.៧. ការត្រួតពិនិត្យគុណភាពសេវាសវនកម្ម

ការធ្វើសវនកម្មដោយសវនករឯករាជ្យ មានគោលបំណងផ្ដល់នូវភាពទុកចិត្តលើគុណភាពនៃរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ។ គុណភាពសេវាសវនកម្ម គឺជាធាតុសារវន្តមួយ ដើម្បីជួយផ្ដល់ការជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុ។

ការត្រួតពិនិត្យលើគុណភាពសេវាសវនកម្ម គឺជាយន្តការបន្ថែមជួយលើកកម្ពស់គុណភាពសេវា-សវនកម្មរបស់សវនករ ក៏ជាយន្តការពង្រឹងភាពដែលអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ។

ចំពោះការត្រួតពិនិត្យគុណភាពសេវាសវនកម្ម **ន.គ.ស.** បានអនុវត្តសាកល្បង (Pilot Project) នាឆ្នាំ២០១៧ តាមរយៈការបង្កើត និងដាក់ឱ្យដំណើរការគណៈកម្មការត្រួតពិនិត្យគុណភាពសវនកម្ម ក្នុងគោលបំណងធានានូវប្រសិទ្ធភាពនៃការអនុវត្តស្តង់ដាសវនកម្មនិងការអះអាង ស្តង់ដាគុណភាពសេវាសវនកម្ម ស្តង់ដាគ្រប់គ្រងគុណភាព និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គណនេយ្យករជំនាញ និងសវនករប្រតិស្រុតដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។

កន្លងមក ការអនុវត្តការចុះត្រួតពិនិត្យ ត្រូវធ្វើឡើងដោយក្រុមអ្នកត្រួតពិនិត្យដែលត្រូវបានជ្រើសរើសដោយគណៈកម្មាធិការត្រួតពិនិត្យ និងជួលពីស្ថាប័នឯកជន ខណៈពេលដែលមន្ត្រីជំនាញរបស់ **ន.គ.ស.** ស្ថិតក្នុងដំណាក់កាលនៃការសិក្សាស្វែងយល់ លើកិច្ចការនេះនៅឡើយ។

ការត្រួតពិនិត្យគុណភាពសេវាសវនកម្មសាកល្បង (Pilot Project) ចាប់ពីឆ្នាំ២០១៧ ដល់២០២២ ត្រូវបានធ្វើឡើងក្រោមជំនួយបច្ចេកទេសរបស់ Institute of Chartered Accountants in English and Wales (ICAEW) និងអ្នកដឹកនាំអ្នកត្រួតពិនិត្យគុណភាពសេវាសវនកម្មមកពី Programma Uitzending Managers (PUM)។

លទ្ធផលនៃការត្រួតពិនិត្យ បង្ហាញថាគុណភាពមិនទាន់មានភាពល្អប្រសើរនៅឡើយ។ ចាប់តាំងពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២២ លទ្ធផលបង្ហាញថា មានក្រុមហ៊ុនសវនកម្មប្រមាណ ២៣.៧៣% ទទួលបានការពេញចិត្ត ឬលទ្ធផលល្អ (Satisfactory) ១៦.៩៥% ត្រូវធ្វើឱ្យប្រសើរឡើងវិញ (Need improvement) និង ៥៩.៣២% មិនទទួលបានការពេញចិត្ត (Unsatisfactory)។ រហូតដល់ពេលនេះ ពុំទាន់មានបទប្បញ្ញត្តិគ្រប់គ្រាន់ដើម្បីដាក់ទោសទណ្ឌលើក្រុមហ៊ុនមិនទទួលបានលទ្ធផលល្អ(មិនគួរជាទីពេញចិត្ត)នៅឡើយ។






## ២.៨. ការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាក្នុងវិស័យគណនេយ្យនិងសវនកម្ម

ដើម្បីឆ្លើយតបនឹងសេដ្ឋកិច្ចឌីជីថល ការរៀបចំប្រព័ន្ធគ្រប់គ្រងក្នុងវិស័យគណនេយ្យនិងសវនកម្ម ត្រូវធ្វើឡើងក្នុងថ្នាលបច្ចេកវិទ្យាព័ត៌មាននិងបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech)។ ក្នុងក្របខណ្ឌនេះ **ន.គ.ស.** បានអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាដើម្បីពង្រឹងការគ្រប់គ្រងនិងលើកកម្ពស់កម្រិតអនុលោមភាព ដែលរួមមាន៖

- ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាស
- ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ
- ប្រព័ន្ធគ្រប់គ្រងការស្នើសុំអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្មតាមអនឡាញ
- ប្រព័ន្ធគ្រប់គ្រងការដាក់ពាក្យស្នើសុំសិក្សាកម្មវិធីគណនេយ្យករជំនាញកម្ពុជា។

ផ្អែកលើភាពចាំបាច់ជាក់ស្តែង **ន.គ.ស.** ត្រូវឈានទៅរៀបចំកម្មវិធីទូរស័ព្ទឆ្លាតវៃសម្រាប់សន្ទានុក្រមវិស័យគណនេយ្យនិងសវនកម្ម ដែលប្រព័ន្ធនេះត្រូវបានរំពឹងថានឹងដាក់ឱ្យដំណើរការក្នុងពេលឆាប់ៗ។

ថ្មីៗនេះ **ន.គ.ស.** បានទទួលការអនុញ្ញាតជាគោលការណ៍ពី **ឯកឧត្តមអគ្គបណ្ឌិត-សភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា អ.ស.ហ.** ដើម្បីអភិវឌ្ឍ "**ថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូចនិងមធ្យម និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ** (Digital Financial Reporting Platform - DFRP)" និងបានរៀបចំរួចរាល់ព្រមទាំងបានដាក់ឱ្យដំណើរការនៅក្នុងវេទិកាជាតិគណនេយ្យឆ្នាំ២០២៤ កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៤។ ថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូចនិងមធ្យម និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ នឹងជួយសម្រួលដល់សហគ្រាសធុនតូចនិងមធ្យមក្នុងការរៀបចំកិច្ចបញ្ជិកាគណនេយ្យ និងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួន ស្របតាមស្តង់ដាជាធរមាន និងជួយលើកកម្ពស់កម្រិតអនុលោមភាព។

## ២.៩. អំពីនិយ័តករគណនេយ្យនិងសវនកម្ម

### ២.៩.១. ក្របខណ្ឌស្ថាប័ន

#### ២.៩.១.១. រចនាសម្ព័ន្ធស្ថាប័ន

បន្ទាប់ពីការបង្កើតគណៈកម្មការសិក្សាស្រាវជ្រាវស្តង់ដាគណនេយ្យអន្តរជាតិ ក្នុងឆ្នាំ១៩៩៩ ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តតាមព្រះរាជក្រមលេខ នស/រកម/០៧០២/ ចុះថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ២០០២។

ផ្អែកតាមច្បាប់នេះ ស្ថាប័នចំនួន២ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៣ គឺទី១.ក្រុមប្រឹក្សាជាតិគណនេយ្យ ដែលជាស្ថាប័នកំណត់ស្តង់ដាគណនេយ្យនិងស្តង់ដាសវនកម្ម និង ទី២.វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ដែលជាស្ថាប័នគ្រប់គ្រងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម។

ការវិវត្តនៃវិស័យគណនេយ្យនិងសវនកម្ម និងវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកលនិងតំបន់ជាបន្តបន្ទាប់ បានជំរុញឱ្យរាជរដ្ឋាភិបាលធ្វើការពិនិត្យសើរើច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ សំដៅពង្រឹងសិទ្ធិអំណាច និងតួនាទីភារកិច្ចរបស់ស្ថាប័នគ្រប់គ្រង និងបង្កើតយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ វិស័យគណនេយ្យនិងសវនកម្ម។ ជាលទ្ធផលក្នុងឆ្នាំ២០១៦ ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ត្រូវបានអនុម័តនិងដាក់ឱ្យប្រើជំនួសច្បាប់ស្តីពីគណនេយ្យ សហគ្រាសសវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យឆ្នាំ២០០២។

នាឆ្នាំ២០២១ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវបានបង្កើតឡើងតាមរយៈច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលជាស្ថាប័នពិនិត្យ រៀបចំនិងដាក់ចេញនូវបទប្បញ្ញត្តិ គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់វិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដោយមាននិយ័តករចំនួន៦ជាតួអង្គប្រតិបត្តិក្រោមឱវាទ ដែលក្នុងនោះមាននិយ័តករគណនេយ្យនិងសវនកម្ម ដែលត្រូវបានប្រែក្លាយពីក្រុមប្រឹក្សាជាតិគណនេយ្យ និងបន្តអនុវត្តមុខងារនិងភារកិច្ចរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ ដូចមានកំណត់ នៅក្នុងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ដើម្បីគ្រប់គ្រងវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា។ ផ្តើមចេញពីច្បាប់នេះ អនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវបានដាក់ឱ្យអនុវត្ត និងបានកំណត់រចនាសម្ព័ន្ធរបស់ **ន.គ.ស.** ដែលដឹកនាំដោយអគ្គនាយក១រូប និងមាននាយកដ្ឋានចំនួន៤ជាសេនាធិការរដ្ឋបាល និងបច្ចេកទេស។

### ២.៩.១.២. ធនធានមនុស្ស

ក្នុងចន្លោះឆ្នាំ២០០៣-២០១៦ មន្ត្រីភាគច្រើនត្រូវបានជ្រើសរើសដោយពុំមានការប្រឡងប្រជែងនោះទេ។ ក្នុងអំឡុងឆ្នាំនោះ មន្ត្រីប្រមាណចំនួន១៩រូប ត្រូវបានជ្រើសរើស និងមានការប្រែប្រួលកើនឡើងជាបន្តបន្ទាប់ ដោយការជ្រើសរើសឈរលើគោលការណ៍គុណវុឌ្ឍិខ្ពស់។ រហូតមកដល់ចុងឆ្នាំ២០២៤ មន្ត្រីសរុបមានចំនួន ១០៥រូប។ មន្ត្រីត្រូវបានចែកចេញជា៤ប្រភេទ គឺ

មន្ត្រីរាជការមុខងារសាធារណៈ មន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.** មន្ត្រីជាប់កិច្ចសន្យារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមន្ត្រីជាប់កិច្ចសន្យារបស់ **អ.ស.ហ.**។ ថ្នាក់ដឹកនាំនិងមន្ត្រីមានជំនាញចម្រុះ រួមមាន ជំនាញគណនេយ្យ ហិរញ្ញវត្ថុ ធនាគារ សវនកម្ម ច្បាប់ រដ្ឋបាល គ្រប់គ្រងសេដ្ឋកិច្ច និងព័ត៌មានវិទ្យា។

### ២.៩.១.៣. ធនធានហិរញ្ញវត្ថុ

ជាកិច្ចដំណើរការ និងការប្រព្រឹត្តទៅរបស់អង្គភាព **ន.គ.ស.** មានប្រភពធនធានហិរញ្ញវត្ថុពីថវិកាជាតិ ថវិកាដៃគូ និងចំណូលផ្ទាល់។ ទោះបីជា **ន.គ.ស.** មានប្រភពថវិកាច្រើន ប៉ុន្តែទំហំកញ្ចប់ថវិកានៅមានកម្រិតតូច ដែលមិនអាចទ្រទ្រង់ការអនុវត្តតួនាទីនិងភារកិច្ចឱ្យបានពេញលេញនៅឡើយទេ ដែលចាំបាច់ត្រូវដោះស្រាយតាមរយៈការពង្រីកមូលដ្ឋាននិងប្រភពចំណូល ដើម្បីធានាការអភិវឌ្ឍ និងគ្រប់គ្រងវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា ប្រកបដោយប្រសិទ្ធភាពនិងចីរភាព។

## ២.៩.២. ក្របខណ្ឌសហប្រតិបត្តិការ

### ២.៩.២.១. កិច្ចសហប្រតិបត្តិការក្នុងប្រទេស

ក្នុងតួនាទីស្នូលជាស្ថាប័នកំណត់ស្តង់ដាគណនេយ្យនិងសវនកម្ម និងជាស្ថាប័ននិយ័តកម្មក្នុងវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា **ន.គ.ស.** បាននិងកំពុងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នសាធារណៈ និងស្ថាប័នឯកជន ក្នុងក្របខណ្ឌការងារលើកកម្ពស់ការយល់ដឹងពីច្បាប់ និងបទប្បញ្ញត្តិគណនេយ្យនិងសវនម្ម តាមរយៈការរៀបចំកម្មវិធីផ្សព្វផ្សាយ និងការបណ្តុះ-បណ្តាល។ លើសពីនេះ កិច្ចសហប្រតិបត្តិការ និងការចែករំលែកទិន្នន័យរបស់សហគ្រាសជាមួយក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារនៅមានកម្រិតនៅឡើយ ដែលទាមទារឱ្យមានការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការបន្ថែមទៀត ដើម្បីឆ្ពោះទៅការសម្រេចឱ្យបានកម្រិតអនុលោមភាពនៃរបាយការណ៍ហិរញ្ញវត្ថុទៅនឹងស្តង់ដាគណនេយ្យជាធរមាន។

បន្ថែមលើកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នសាធារណៈ **ន.គ.ស.** ត្រូវបានមើលឃើញថាបានខិតខំធ្វើកិច្ចសហប្រតិបត្តិការយ៉ាងខ្លាំងជាមួយនិយ័តករនិងអង្គភាពនានា ក្រោមឱវាទ **អ.ស.ហ.** លើការងារផ្តល់ប្រឹក្សាយោបល់លើលិខិតបទដ្ឋានគតិយុត្ត ការចែករំលែកចំណេះដឹងនិងបទពិសោធន៍ក្នុងវិស័យ សំដៅដល់ការសម្រេចគោលដៅនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥។

### ២.៩.២.២. កិច្ចសហប្រតិបត្តិការអន្តរជាតិ

ក្នុងក្របខណ្ឌអន្តរជាតិ **ន.គ.ស.** បានដើរតួនាទីជាសេនាធិការឱ្យ **អ.ស.ហ.** ដោយបានចូលរួមក្នុងឋានៈ ជាសមាជិកនៃស្ថាប័នបច្ចេកទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ដែលរួមមាន៖ International Accounting Standard Board-IASB, International Federation of Accountants-IFAC, International Standards of Accounting and Reporting-ISAR, Asian- Oceanian Standard-Setters Group-AOSSG, Public Company Accounting Oversight Board-PCAOB, International Public Sector Accounting Standard Board-IPSASB, International Audit and Assurance Standard Board-IAASB, International Ethics Standards Board for Accountants-IEASB, ASEAN Federation of Accountants-AFA, ASEAN Chartered Professional Accountant Coordinating Committee -ACPACC, Association of Chartered Certified Accountants-ACCA, CPA Australia និងស្ថាប័នអន្តរជាតិពាក់ព័ន្ធដទៃទៀត ព្រមទាំងបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តកិច្ចព្រមព្រៀងអញមញ្ញក្នុងក្របខណ្ឌ ASEAN Mutual Recognition Arrangements (MRAs)។

## ២.១០. ការវិភាគស្ថានភាពបច្ចុប្បន្ន (SWOT ANALYSIS)

### ២.១០.១. ភាពខ្លាំង (Strengths)

- ប្រទេសកម្ពុជាមានសុខសន្តិភាពពេញលេញនិងស្ថិរភាពនយោបាយ ដែលអំណោយផលដល់ការរីកលូតលាស់នៃសេដ្ឋកិច្ចជាតិ
- មានស្ថាប័នគ្រប់គ្រងវិស័យនិងវិជ្ជាជីវៈ ដែលត្រូវបានបង្កើតឡើងដោយច្បាប់ និងបានកំណត់ច្បាស់លាស់នូវ មុខងារនិងភារកិច្ច, ប្រភពហិរញ្ញវត្ថុទ្រទ្រង់ស្ថាប័ន, រចនាសម្ព័ន្ធស្ថាប័ននិងចាត់តាំងជាក់លាក់
- ការយល់ដឹងអំពីសារៈសំខាន់នៃវិស័យគណនេយ្យនៅក្នុងសេដ្ឋកិច្ចនិងធុរកិច្ចពីសំណាក់ធុរជននិងវិនិយោគិន មានការកើនឡើងជាបណ្តើរៗ
- មន្ត្រីគ្រប់លំដាប់ថ្នាក់មានឆន្ទៈក្នុងការបំពេញការងារ។

### ២.១០.២. ភាពខ្សោយ (Weaknesses)

- សមត្ថភាពស្ថាប័ននៅមានកម្រិត ដែលជាឧបសគ្គនៅក្នុងការគ្រប់គ្រងនិងអភិវឌ្ឍវិស័យគណនេយ្យ និងសវនកម្ម

- មូលធនមនុស្សជាគណនេយ្យករជំនាញ និងបុគ្គលិកគណនេយ្យដែលមានគុណវុឌ្ឍិ មិនទាន់មានចំនួនគ្រប់គ្រាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងអាចនាំឱ្យមានយឺតយ៉ាវ ក្នុងការធ្វើឱ្យអនុលោមភាពនៃរបាយការណ៍ហិរញ្ញវត្ថុទៅនឹងស្តង់ដាគណនេយ្យជាធរមាន
- អនុលោមភាពគតិយុត្តិ និងអនុលោមភាពបច្ចេកទេសស្តង់ដា ដោយសហគ្រាសនិង អង្គភាពមិនស្វែងរកប្រាក់ចំណេញ នៅមានកម្រិត
- កម្មវិធីសិក្សាគណនេយ្យកម្រិតមូលដ្ឋានក្នុងក្របខណ្ឌបណ្ឌិតសភា (Academic) មិនទាន់មានភាពជឿនលឿនស្របតាមការវិវត្តនៃវិស័យនេះនៅក្នុងតំបន់និងសាកលលោក
- គុណភាពសវនកម្មនៅមានកម្រិត ជាបញ្ហាមួយសម្រាប់ក្រុមហ៊ុនសវនកម្ម ក្នុងការធានា បាន នូវកម្រិតខ្ពស់នៃតម្លាភាពនិងភាពអាចទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុរបស់ សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ
- កង្វះថ្នាលឌីជីថលគ្រប់ និងបរិស្ថានគោលនយោបាយអំណោយផល ព្រមទាំងក្របខណ្ឌ គតិយុត្តិសម្រាប់អភិវឌ្ឍន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យគណនេយ្យនិង សវនកម្ម ដើម្បីសម្រេចឱ្យបាននូវបំណងប្រាថ្នានៃសេដ្ឋកិច្ចនិងរដ្ឋាភិបាលឌីជីថល
- កង្វះកិច្ចសហការរវាងអន្តរស្ថាប័ន ជាឧបសគ្គមួយចំណែកដល់ការរីកលូតលាស់នៃ វិស័យគណនេយ្យនិងសវនកម្ម។

### ២.១០.៣. កាលានុវត្តភាព (Opportunities)

- និយ័តករបានផ្លាស់ប្តូរក្របខណ្ឌគតិយុត្តថ្មី ដែលមានឯករាជ្យភាពក្នុងការបំពេញការងារ
- ការដាក់ចេញយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដោយរាជរដ្ឋាភិបាលក្លាយជា មគ្គុទេសក៍គោលសម្រាប់ **ន.គ.ស.** ក្នុងការពង្រឹងតួនាទី និងភារកិច្ចក្រោមការទទួល ខុសត្រូវ
- ការដាក់ចេញក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចឌីជីថល ដោយរាជរដ្ឋាភិបាលនឹងធ្វើឱ្យ មានការបង្កើតនិងប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មកាន់តែច្រើនក្នុងទីផ្សារ
- ការព្យាករនៃការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជាក្រោមលក្ខខណ្ឌសុខសន្តិភាព និង ស្ថិរភាពនយោបាយ ត្រូវបានរំពឹងថានឹងមានសកម្មភាពសេដ្ឋកិច្ចកាន់តែច្រើនតាមរយៈ ការវិនិយោគថ្មីៗពីបរទេស និងក្នុងស្រុក ដែលជាកត្តាជំរុញឱ្យមានតម្រូវការលើការប្រើប្រាស់ ធនធានមនុស្ស ជំនាញគណនេយ្យនិងសវនកម្មកាន់តែច្រើន
- នវានុវត្តន៍នៃបច្ចេកវិទ្យាហិរញ្ញវត្ថុនឹងរួមចំណែកនៅក្នុងការពង្រឹងនិងការអភិវឌ្ឍវិស័យ គណនេយ្យ។

#### ២.១០.៤. ការគំរាមកំហែង (Threats)

- ការយល់ដឹងរបស់ធុរជន និងវិនិយោគិនអំពីសារៈប្រយោជន៍នៃការកាន់បញ្ជីគណនេយ្យ និងកាតព្វកិច្ចគណនេយ្យនិងសវនកម្ម នៅមានកម្រិត ពោលគឺមិនទាន់មានវប្បធម៌គណនេយ្យ
- វិបត្តិសេដ្ឋកិច្ចដែលកើតចេញពីការរីករាលដាលនៃជំងឺកូវីដ-១៩ និងភាពមិនប្រាកដប្រជានៃសង្គ្រាមនៅអឺរ៉ុបខាងកើត និងនៅមជ្ឈឹមបូព៌ា បានប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជា និងជះឥទ្ធិពលដល់ការគោរពច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។

### ២.១១. ចក្ខុវិស័យ គោលបំណង គោលដៅ បេសកកម្ម និងគុណតម្លៃស្នូល

#### ២.១១.១. ចក្ខុវិស័យ

ចក្ខុវិស័យនៃការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា គឺការប្រែក្លាយ "**កាតព្វកិច្ចគណនេយ្យនិងសវនកម្មរបស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ**" ទៅជា "**វប្បធម៌គណនេយ្យនិងសវនកម្ម**" ប្រកបដោយនិរន្តរភាព។

#### ២.១១.២. គោលបំណង

យុទ្ធសាស្ត្រនេះមានគោលបំណងធានាប្រសិទ្ធភាព និងសក្តិសិទ្ធភាពនៃការអភិវឌ្ឍនិងការគ្រប់គ្រងវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា។

#### ២.១១.៣. គោលដៅ

យុទ្ធសាស្ត្រនេះមានគោលដៅរៀបចំ និងដាក់ឱ្យអនុវត្តនូវសកម្មភាពជាយុទ្ធសាស្ត្រសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ដើម្បីធ្វើជាមូលដ្ឋាននិងជាមគ្គុទេសន៍សម្រាប់ **ន.គ.ស.** អនុវត្តដើម្បីសម្រេចឱ្យបាននូវគោលដៅយុទ្ធសាស្ត្រដែលបានដាក់ចេញ។

#### ២.១១.៤. បេសកកម្ម

**ន.គ.ស.** មានបេសកកម្មគ្រប់គ្រងនិងអភិវឌ្ឍវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មតាមរយៈការកំណត់ស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម និងស្តង់ដាពាក់ព័ន្ធ សម្រាប់វិស័យសាធារណៈ វិស័យឯកជន និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ព្រមទាំងអនុវត្តយន្តការគ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃអនុលោមភាព ធានាប្រសិទ្ធភាពនិងសក្តិសិទ្ធភាពនៃការគ្រប់គ្រងវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្មនៅកម្ពុជា។

### ២.១១.៥. គុណតម្លៃស្ថាប័ន

- **ក្រមសីលធម៌វិជ្ជាជីវៈ៖** ការប្រតិបត្តិតាមគោលការណ៍សីលធម៌ ដែលកំណត់នូវសកម្មភាព និងអាកប្បកិរិយាក្នុងពេលបំពេញការងារ ដើម្បីរក្សាគុណតម្លៃ កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃមន្ត្រីរាជការ តាមរយៈ ការប្រកាន់ខ្ជាប់ឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ ព្រមទាំងគោរពបានយ៉ាងខ្ជាប់ខ្ជួននូវអភិក្រមការងារ ៤ ប្រការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- **ស្មារតីបុរេសកម្ម៖** ការគិតយល់មុននូវលទ្ធភាពកើតមានបញ្ហា ការប្រកាន់យកគោលការណ៍មិនបង្កើតបញ្ហា ការរៀបចំប្រព័ន្ធការងារដែលកាត់បន្ថយលទ្ធភាពកើតមានបញ្ហា ការត្រៀមលក្ខណៈសកម្មជានិច្ច ការត្រៀមដោះស្រាយបញ្ហាជាយថាហេតុ ការមិនមើលបំណាំ ការមិនចោទប្រកាន់គ្នា ការគិតគូរដោះស្រាយបញ្ហាទាន់នៅទំហំតូច និងចាត់វិធានការជាមុនដោយមិនរង់ចាំការណែនាំ។
- **ប្រតិគុណ្យការ៖** ការពិចារណា ថ្លឹងថ្លែង បែងចែកតួនាទី ភារកិច្ច និងសិទ្ធិសម្រេចប្រកបដោយយុត្តិធម៌ ដើម្បីធ្វើឱ្យថ្នាក់ដឹកនាំ អង្គភាព និងមន្ត្រីគ្រប់លំដាប់ថ្នាក់មានលំនឹងចិត្ត ការជឿជាក់ និងការទទួលខុសត្រូវច្បាស់លាស់ ក្នុងការអនុវត្តតួនាទី ភារកិច្ច ដោយឈរលើមាគ៌ាសុចរិត យុត្តិធម៌ បម្រើឧត្តមប្រយោជន៍ជាតិ និងប្រជាជន។
- **ប្រសិទ្ធភាព និងសក្តិសិទ្ធភាព៖** ការផ្តោតការយកចិត្តទុកដាក់លើគុណភាពនៃលទ្ធផល ភាពសមស្របនៃចំណាយ និងវិធីសាស្ត្រប្រតិបត្តិការ ដោយប្រកាន់ជំហរ "**គិតត្រូវ ធ្វើត្រូវ ចំណាយតិច បានផលអតិបរមា**"។
- **នវានុវត្តន៍៖** ការប្រើគំនិតកែច្នៃ និងការចូលរួមដោះស្រាយបញ្ហាប្រឈមជាក់ស្តែងតាមរយៈ ការបង្កើតដំណោះស្រាយថ្មី ឬការច្នៃប្រឌិតលើស្នាដៃដែលមានស្រាប់ ដែលបង្កើតជាតម្លៃបន្ថែម។
- **គុណាធិបតេយ្យ៖** ប្រព័ន្ធលើកទឹកចិត្តសមស្រប ផ្អែកលើសមត្ថភាព សមិទ្ធកម្ម ប្រសិទ្ធភាព វិន័យ នវានុវត្តន៍ និងសមធម៌ ដែលធានាសុចរិតភាព និរន្តរភាព និងកិត្យានុភាពស្ថាប័ន តាមគោលការណ៍ "**លើកទឹកចិត្តផ្អែកលើគុណសម្បត្តិ និងបង្កើតគុណសម្បត្តិដើម្បីបានការលើកទឹកចិត្ត**"។

## ៣. ផែនការយុទ្ធសាស្ត្រ ២០២៥-២០៣៥

### ៣.១. ក្របខណ្ឌបញ្ញត្តិកម្ម

ដើម្បីអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជាឱ្យទទួលបានជោគជ័យ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារនឹងផ្តល់ការពិនិត្យ និងអនុម័តលើបទប្បញ្ញត្តិចាំបាច់ពាក់ព័ន្ធដែលបានស្នើឡើងដោយនិយ័តករគណនេយ្យនិងសវនកម្ម សំដៅបំពេញបន្ថែមលើចំណុចខ្វះខាតក្នុងការអនុវត្ត។

**ក.បទប្បញ្ញត្តិដែលត្រូវធ្វើវិសោធនកម្ម ឬកែសម្រួលបំពេញបន្ថែម**

- ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ឆ្នាំ២០១៦
- អនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
- ប្រកាសស្តីពីការគ្រប់គ្រងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម សម្រាប់ជនបរទេស។

**ខ.បទប្បញ្ញត្តិដែលត្រូវរៀបចំបន្ថែម**

- ប្រកាសស្តីពីការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ កម្រិត២
- ប្រកាសស្តីពីការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសាមញ្ញកម្ពុជា
- ប្រកាសស្តីពីការត្រួតពិនិត្យគុណភាពសវនកម្ម និងការអះអាង
- ប្រកាសស្តីពីការដាក់ឱ្យអនុវត្តថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់សហគ្រាសធុនតូចនិងមធ្យម និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ
- ប្រកាសស្តីពីវិធាននិងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាចំពោះសេចក្តីសម្រេចពិន័យអន្តរការណ៍
- ប្រកាសស្តីពីកាតព្វកិច្ចដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ
- ប្រកាសស្តីពីការដាក់ឱ្យអនុវត្តបែបបទ និងនីតិវិធីនៃការដោះស្រាយវិវាទក្នុងវិស័យគណនេយ្យនិងសវនកម្ម

- ប្រកាសស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម (ថ្មី)
- ប្រកាសស្តីពីទណ្ឌកម្មរដ្ឋបាលចំពោះអំពើល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម
- ប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការត្រួតពិនិត្យកាតព្វកិច្ចគណនេយ្យនិងសវនកម្ម របស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញដែលមានហានិភ័យ
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀត ដែលគាំទ្រដល់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុមិនមែនធនាគារ និងការទប់ស្កាត់ប្រតិបត្តិការលាងសម្អាតប្រាក់និងហិរញ្ញប្បទានអាវុធមហាប្រល័យ ក្នុងវិស័យគណនេយ្យនិងសវនកម្ម។

គោលបំណងនៃការដាក់ចេញនូវបទប្បញ្ញត្តិខាងលើគឺ ដើម្បីសម្រួលដល់បរិយាកាសធ្វើធុរកិច្ចកាន់តែប្រសើរថែមទៀត ទាក់ទាញការវិនិយោគពីបរទេស បង្កើនចំណូលជាតិ និងគាំទ្រដល់ចក្ខុវិស័យរបស់ប្រទេសកម្ពុជា ឆ្នាំ២០៣០ ដែលនឹងក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់។

## ៣.២. ក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្ម

វិស័យគណនេយ្យនិងសវនកម្ម ដែលរួមបញ្ចូលទាំងការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈគណនេយ្យ និងការគ្រប់គ្រងការផ្តល់សេវាវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម បានកំពុងនិងបន្តដើរតួនាទីយ៉ាងសំខាន់ដើម្បីបង្កើន តម្លាភាព គណនេយ្យភាព និងភាពជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុសម្រាប់តួអង្គពាក់ព័ន្ធ ជាពិសេស វិនិយោគិន ម្ចាស់ភាគហ៊ុន ស្ថាប័នផ្តល់កម្ចី រាជរដ្ឋាភិបាល ជាដើម និងមានវិសាលភាពគ្របដណ្តប់គ្រប់វិស័យ គ្រប់ទម្រង់នៃសកម្មភាពសេដ្ឋកិច្ច។ កិច្ចការគណនេយ្យត្រូវបានចាត់ទុកថាជាស្នូល និងជាប្រភពនៃព័ត៌មានហិរញ្ញវត្ថុដែលមិនអាចខ្វះបានសម្រាប់ភាគីពាក់ព័ន្ធដើម្បីធ្វើជាមូលដ្ឋានចម្បងសម្រាប់ធ្វើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច និងដើម្បីបំពេញអនុលោមភាពតាមច្បាប់។ កិច្ចការសវនកម្មនឹងជួយអះអាងបញ្ជាក់បន្ថែមដល់តួអង្គពាក់ព័ន្ធលើភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃព័ត៌មានហិរញ្ញវត្ថុដែលត្រូវបានដាក់បង្ហាញតាមរយៈរបាយការណ៍ហិរញ្ញវត្ថុជាមួយនឹងមតិសវនកម្មរបស់សវនករឯករាជ្យ។ ក្នុងរយៈពេលវែង ការប្រែក្លាយពី **"កាតព្វកិច្ចគណនេយ្យ និងសវនកម្ម"** ទៅជា **"វប្បធម៌គណនេយ្យនិងសវនកម្ម"** គឺបំណងប្រាថ្នាមួយរបស់រាជរដ្ឋាភិបាល, **ន.គ.ស.** និងភាគីពាក់ព័ន្ធនានា ត្រូវរួមគ្នាសម្រេចឱ្យបាន។

ដូច្នេះ ដើម្បីអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជាឱ្យទទួលបានជោគជ័យ **ន.គ.ស.** បានកំណត់គោលដៅជាយុទ្ធសាស្ត្រគឺ **"ប្រព័ន្ធគណនេយ្យនិងសវនកម្មដែលរឹងមាំមានតម្លាភាព និងអាចជឿទុកចិត្តបាន"** ដោយស្តែងឡើងតាមរយៈសសរស្តម្ភចំនួន ៦ (Pillars) គឺ៖

១. ការពង្រឹង និងពង្រីកសមត្ថភាពរបស់ស្ថាប័ន
២. ការកសាងមូលធនមនុស្សជំនាញគណនេយ្យនិងសវនកម្មសម្រាប់ទីផ្សារ
៣. ការដាក់ឱ្យអនុវត្តស្តង់ដាបច្ចេកទេស
៤. ការលើកកម្ពស់កម្រិតអនុលោមភាព
៥. ការលើកកម្ពស់គុណភាពសវនកម្ម និងការអះអាង
៦. ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យគណនេយ្យនិងសវនកម្ម។

### ៣.២.១. សសរស្តម្ភទី១៖ ការពង្រឹង និងពង្រីកសមត្ថភាពរបស់ស្ថាប័ន

ផ្អែកលើផែនការអភិវឌ្ឍន៍ស្ថាប័នបច្ចុប្បន្នកម្មរយៈពេល ១០ឆ្នាំ (២០២១-២០៣០) របស់និយ័តករគណនេយ្យនិងសវនកម្ម ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នៅក្នុងកិច្ចប្រជុំលើកទី១៧ អាណត្តិទី១ កាលពីថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៤ **ន.គ.ស.** ត្រូវអនុវត្ត សម្រេចឱ្យបាននូវគោលដៅចំនួន៦ សម្រាប់រយៈពេល ១០ឆ្នាំ ដែលមានដូចខាងក្រោម៖

- អភិបាលកិច្ចល្អ និងការគ្រប់គ្រងស្ថាប័ន
- រចនាសម្ព័ន្ធចាត់តាំងនិងប្រព័ន្ធលើកទឹកចិត្ត
- ធនធានមនុស្ស និងការកសាងសមត្ថភាពជំនាញ
- ទីកន្លែងបំពេញការងារ និងសម្ភារៈ បរិក្ខារ
- សេវាសាធារណៈឆ្លើយតបទៅនឹងបរិការណ៍សេដ្ឋកិច្ចឌីជីថល
- កិច្ចសហប្រតិបត្តិការ។

ទន្ទឹមនេះ **ទ.គ.ស.ក.** ដែលជាតួអង្គសំខាន់មួយក្នុងការគ្រប់គ្រងវិជ្ជាជីវៈ ត្រូវរៀបចំ និងដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ស្ថាប័នរបស់ខ្លួនឱ្យបានឆាប់រហ័សជាមួយនឹងផែនការសកម្មភាពគាំទ្រដល់ការសម្រេចឱ្យបានគោលដៅជាយុទ្ធសាស្ត្រនៃឯកសារនេះ។

*គោលដៅយុទ្ធសាស្ត្រ (Strategic objectives) នៃសសរស្តម្ភទី១ គឺស្ថាប័ននិយ័តកម្មមួយដែលមានភាពធន់ មានសមត្ថភាពខ្ពស់ មានដំណើរការល្អ និងប្រកបដោយវិជ្ជាជីវៈ ដើម្បីសម្រេចបាននូវបេសកកម្មចម្បងរបស់ស្ថាប័ន។*

ដូច្នេះ ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រនេះ សកម្មភាពដែលនឹងត្រូវយកចិត្តទុកដាក់រួមមាន ១).ការរៀបចំ រចនាសម្ព័ន្ធស្ថាប័នមួយដែលមានភាពធន់, ២).រៀបចំនិងស្នើឡើងនូវក្របខណ្ឌគតិយុត្តគ្រប់គ្រាន់សម្រាប់ធានាអភិបាលកិច្ចល្អស្ថាប័ន, ៣).អភិវឌ្ឍមូលធនមនុស្សជាមន្ត្រីដែលមានគុណវុឌ្ឍិខ្ពស់ និងមានចំនួនគ្រប់គ្រាន់, ៤).បង្កើត និងរក្សាបរិស្ថានការងារនិង

ប្រព័ន្ធលើកទឹកចិត្តដែលជានាបានផលិតភាពការងារខ្ពស់, ៥).សេវាសាធារណៈឆ្លើយតបទៅនឹងបរិការណ៍សេដ្ឋកិច្ចឌីជីថល, និង៦).ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការល្អរវាងអង្គភាពពាក់ព័ន្ធនានា។

### ៣.២.២. សសរស្តម្ភទី២៖ ការកសាងមូលធនមនុស្សជំនាញគណនេយ្យ និងសវនកម្មសម្រាប់ទីផ្សារ

នៅកម្ពុជា ការបង្កើតជំនាញគណនេយ្យ និងសវនកម្ម អាចធ្វើឡើងតាមរយៈទិដ្ឋភាពចំនួនពីរ គឺទិដ្ឋភាពអប់រំ ឬបណ្ឌិតសភា (Academic aspect) និងទិដ្ឋភាពវិជ្ជាជីវៈ (Professional aspect)។

សម្រាប់ទិដ្ឋភាពបណ្ឌិតសភា សាកលវិទ្យាល័យ ឬគ្រឹះស្ថានឧត្តមសិក្សាជាច្រើន បាននិងកំពុងបណ្តុះបណ្តាលមុខវិជ្ជាគណនេយ្យនិងសវនកម្ម ក្នុងកម្រិតសិក្សាថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ដោយផ្តល់សញ្ញាបត្រក្រោមជំនាញផ្សេងៗគ្នា។ ជារៀងរាល់ឆ្នាំ និស្សិតជំនាញគណនេយ្យ និងសវនកម្ម រាប់ពាន់នាក់ បានបញ្ចប់ការសិក្សារបស់ខ្លួន ដែលនិស្សិតខ្លះបានបន្តការសិក្សាក្នុងកម្រិតបន្ទាប់ និស្សិតខ្លះទៀតបានបើកអាជីវកម្ម បង្កើតមុខរបរដោយខ្លួនឯង និងនិស្សិតខ្លះទៀតទទួលបានការងារនៅតាមស្ថាប័នរដ្ឋ ឯកជន និងអង្គការក្រៅរដ្ឋាភិបាល។ តាមរយៈវេទិកាការងារនាពេលកន្លងមក និយោជកបានបង្ហាញពីការលំបាកក្នុងការជ្រើសរើសបុគ្គលិកជំនាញគណនេយ្យ និង/ឬសវនកម្ម ដើម្បីឱ្យទៅបម្រើការងារឱ្យក្រុមហ៊ុនដែលអាចជាក្រុមហ៊ុនគណនេយ្យ ឬសវនកម្ម (Accounting/ Auditing Firms) ឬ ក្រុមហ៊ុនអាជីវកម្ម (Corporates)។

ចំណែកទិដ្ឋភាពវិជ្ជាជីវៈ តាមរយៈកិច្ចព្រមព្រៀងដែលធ្វើឡើងដោយ **ន.គ.ស.** និង **វ.គ.ស.ក.** និងស្ថាប័នវិជ្ជាជីវៈក្រៅប្រទេស រួមមាន៖ ស្ថាប័នអេស៊ីស៊ីអេ (Association of Certified Chartered Accountants-ACCA) និងស្ថាប័ន ស៊ីភីអេ អូស្ត្រាលី (CPA Australia) បានអនុញ្ញាតឱ្យជនជាតិខ្មែរអាចចុះឈ្មោះចូលរៀន និងប្រឡងយកសញ្ញាបត្រគណនេយ្យករជំនាញដែលចេញដោយស្ថាប័នវិជ្ជាជីវៈទាំងពីរ។ លទ្ធផលដែលទទួលបានពីការបណ្តុះបណ្តាលតាមរយៈកម្មវិធីសិក្សាគណនេយ្យករជំនាញបរទេសទាំងពីរខាងលើ នៅមានកម្រិតនៅឡើយ ដែលមិនអាចឆ្លើយតបទៅនឹងតម្រូវការសេវាវិជ្ជាជីវៈក្នុងក្របខណ្ឌនៃសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ននិងអនាគត។ ដើម្បីដោះស្រាយក្តីបារម្ភខាងលើ រាជរដ្ឋាភិបាលតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបង្កើតគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ និងបានដាក់ឱ្យអនុវត្តកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជាក្នុងឆ្នាំ២០២១ សំដៅបង្កើតជម្រើសជូនប្រជាពលរដ្ឋកម្ពុជាអាចសិក្សាដើម្បីក្លាយខ្លួនជាគណនេយ្យករជំនាញកម្ពុជាបានលឿន និងមានគុណភាពឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់កម្ពុជា។

*គោលដៅយុទ្ធសាស្ត្រ (Strategic objectives) នៃសសរស្តម្ភទី២ គឺភាពសម្បូរបែបនិងគុណវុឌ្ឍិនៃមូលធនមនុស្សក្នុងជំនាញគណនេយ្យនិងសវនកម្ម និងអាចផ្គត់ផ្គង់តម្រូវការទីផ្សារឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាសម្រាប់រយៈពេល១០ឆ្នាំ (២០២៥-២០៣៥) ព្រមទាំងរួមចំណែកនៅក្នុងការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ។*

ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រនេះ សកម្មភាពដែលនឹងត្រូវបានយកចិត្តទុកដាក់រួមមាន៖ ១).ការធ្វើទំនើបកម្មបន្ថែមកម្មវិធីសិក្សាជំនាញគណនេយ្យនិងសវនកម្មនៅគ្រឹះស្ថានឧត្តមសិក្សា និងស្ថាប័នបណ្តុះបណ្តាលនានា ដែលជឿនលឿនស្របតាមការវិវត្តរបស់ពិភពលោក, ២).ការលើកកម្ពស់គុណវុឌ្ឍិសាស្ត្រាចារ្យជំនាញគណនេយ្យនិងសវនកម្ម, ៣).ការជំរុញវឌ្ឍនភាពកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា (Cambodia Certified Public Accountants Program-Cambodia CPA) និងកម្មវិធីបច្ចេកទេសគណនេយ្យ (Accounting Technician Qualification - ATQ) ទន្ទឹមគ្នានឹងការបន្តទទួលស្គាល់កម្មវិធីសិក្សាជាលក្ខណៈអន្តរជាតិជាមួយនិងស្ថាប័នដែលពាក់ព័ន្ធ, ៤).ភាពជាម្ចាស់នៃការបណ្តុះបណ្តាលគណនេយ្យជំនាញជាតិ និងអ្នកបច្ចេកទេសគណនេយ្យ និង ៥).ការបង្កើតថ្នាលឌីជីថលសម្រាប់កម្មវិធីសិក្សានិងការប្រឡង។

### ៣.២.៣. សសរស្តម្ភទី៣៖ ការដាក់ឱ្យអនុវត្តស្តង់ដាបច្ចេកទេស

ទោះបីជាស្តង់ដាគណនេយ្យសាធារណៈ ស្តង់ដាគណនេយ្យឯកជន ស្តង់ដាគណនេយ្យសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ស្តង់ដាសវនកម្ម និងស្តង់ដាការអះអាងជាលក្ខណៈអន្តរជាតិ ត្រូវបានដាក់ឱ្យអនុវត្តទាំងស្រុងនៅកម្ពុជាយ៉ាងណាក៏ដោយ ក៏បញ្ហាប្រឈមនិងការលំបាកនៅតែកើតមានឡើងសម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ជាពិសេស សហគ្រាសធុនតូច និងមធ្យម។ ករណីនេះ ក៏មានការស្នើឱ្យមានការគិតគូទៅលើការដាក់ចេញនូវស្តង់ដាគណនេយ្យសាមញ្ញមួយដែលនឹងផ្តល់ភាពងាយស្រួលដល់សហគ្រាស ដែលជាសហគ្រាសធុនតូច និងមីក្រូ-សហគ្រាសអាចអនុវត្តបាន ចំណាយតិច និងចូលរួមបំពេញអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិដែលបានតម្រូវ។ ជាមួយគ្នានេះ តាមរយៈវេទិកានានា អង្គការសង្គមស៊ីវិលបានលើកឡើងពីការលំបាកនៅក្នុងការជ្រើសរើសយកស្តង់ដាគណនេយ្យជាធរមាន ដើម្បីធ្វើគណនេយ្យកម្ម និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយហេតុថា ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម (CIFRS for SMEs) មានកម្រិតស្មុគស្មាញខ្លាំង ហើយស្តង់ដាគណនេយ្យមូលដ្ឋានសាច់ប្រាក់សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ មានលក្ខណៈសម្បត្តិមិនសមស្របតាមប្រភេទប្រតិបត្តិការរបស់អង្គការ សមាគម ដែលទាមទារការគិតគូរបន្ថែមលើ

ការរៀបចំស្តង់ដាគណនេយ្យមូលដ្ឋានបង្គរសាមញ្ញមួយទៀតដែលស្ថិតនៅចន្លោះកណ្តាល នៃស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម (CIFRS for SMEs) និងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់-ចំណេញ (CFRS for NFPEs)។ លើសពីនេះ ខ្លឹមសារបកប្រែស្តង់ដាជាខេមរភាសា ត្រូវបានទទួលស្គាល់ថា មិនទាន់មានភាពពេញលេញច្បាស់លាស់ និងងាយស្រួលយល់នៅឡើយ។

*គោលដៅយុទ្ធសាស្ត្រ (Strategic objectives) នៃសសរស្តម្ភទី៣ គឺសុខដុមនីយកម្មនៃស្តង់ដាគណនេយ្យនិងសវនកម្មរបស់ជាតិជាមួយ ស្តង់ដាគណនេយ្យនិងសវនកម្មអន្តរជាតិ និងធានាបានថា គ្រប់វិស័យនិងទំហំអាជីវកម្ម មានស្តង់ដាប្រើប្រាស់ និងស្របតាមលក្ខខណ្ឌនានាដែលកំណត់ដោយច្បាប់និងបទដ្ឋានគតិយុត្តជាធរមាន។*

ដើម្បីសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រនេះ សកម្មភាពជាយុទ្ធសាស្ត្រ ដែលត្រូវយកចិត្តទុកដាក់ជាអាទិ៍៖ ១).ការបន្តអនុវត្តស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្មនិងការអះអាង និងក្រមសីលធម៌វិជ្ជាជីវៈ ដែលដាក់ចេញដោយស្ថាប័នកំណត់ស្តង់ដាអន្តរជាតិ ព្រមទាំងបច្ចុប្បន្នភាពនានា និងការបង្កើតយន្តការអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីធានាបានកម្រិតអនុលោមភាព និងប្រសិទ្ធភាពខ្ពស់, ២).ការស្នើរៀបចំ និងស្នើដាក់ឱ្យអនុវត្តក្របខណ្ឌកាត់បន្ថយការដាក់បង្ហាញដោយផ្អែកតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យមដែលមិនរងសវនកម្ម, ៣).ការធានាថាស្តង់ដាគណនេយ្យសាធារណៈកម្ពុជាត្រូវបានអនុវត្តស្របតាមផែនទីបង្ហាញផ្លូវ ដូចបានកំណត់នៅក្នុងឯកសារយុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា២០២១-២០៣១, ៤).ការធានាថាគ្រឹះស្ថានសាធារណៈរដ្ឋបាលមានស្តង់ដាគណនេយ្យសម្រាប់ប្រើ, ៥).ការរៀបចំនិងដាក់ឱ្យអនុវត្តមាតិកាគណនេយ្យនៃប្លង់គណនេយ្យសហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ៦).ការស្នើដាក់ឱ្យអនុវត្តស្តង់ដាការលាតត្រដាងព័ត៌មានអំពីចីរភាព (Sustainability Disclosure Standards) ដើម្បីបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ (Sustainable Development Goals 2030) និង៧).ការស្នើដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញមូលដ្ឋានសាច់ប្រាក់កែសម្រួល និងមូលដ្ឋានបង្គរ។

### ៣.២.៤. សសរស្តម្ភទី៤៖ ការលើកកម្ពស់កម្រិតអនុលោមភាព

យោងតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្មឆ្នាំ២០១៦ កាតព្វកិច្ចស្នូលចំនួនបី ត្រូវបានកំណត់សម្រាប់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ គឺកាតព្វកិច្ចកាន់បញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ កាតព្វកិច្ចរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន និង

កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ។ ការអនុវត្តកាតព្វកិច្ចទាំងបី គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការលើកកម្ពស់កម្រិតអនុលោមភាព និងជានាបានថាប្រព័ន្ធគណនេយ្យរបស់កម្ពុជាមានភាពរឹងមាំ និងអាចជឿទុកចិត្តបាន។ តាមរយៈវត្តមាននៃច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម អនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ត្រូវបានរាជរដ្ឋាភិបាលដាក់ឱ្យអនុវត្តក្នុងគោលដៅពង្រឹងអនុលោមភាពនៃច្បាប់ និងលើកកម្ពស់តម្លាភាព និងភាពជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ សំដៅទាក់ទាញការវិនិយោគបន្ថែមពីបរទេស និងបង្កើនចំណូលថវិការដ្ឋ។ ដើម្បីអាចវាស់វែងបានពីកម្រិតអនុលោមភាពនៃរបាយការណ៍ហិរញ្ញវត្ថុចំពោះច្បាប់និងបច្ចេកទេសស្តង់ដាគណនេយ្យជាធរមាន សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវបានតម្រូវឱ្យដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៅ **ន.គ.ស.** នៃ **អ.ស.ហ.** ដោយកំណត់យកការិយបរិច្ឆេទគណនេយ្យ២០២០ ជាឆ្នាំដំបូងសម្រាប់សហគ្រាសរងសវនកម្មឯករាជ្យ និងការិយបរិច្ឆេទគណនេយ្យ២០២១ សម្រាប់សហគ្រាសមិនរងសវនកម្មឯករាជ្យ និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ។

យន្តការដែលបានដាក់ចេញដើម្បីជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងគណនេយ្យ និងសវនកម្ម នាពេលកន្លងមក អាចត្រូវបានចាត់ទុកថា ជាការជោគជ័យបានមួយកម្រិតរួចទៅហើយ ប៉ុន្តែការអនុវត្តជាទូទៅបានជួបប្រទះឧបសគ្គមួយចំនួន ក្នុងនោះរួមមាន៖ ក្របខណ្ឌច្បាប់មិនទាន់រឹងមាំ, ចំណេះដឹងពីសារៈសំខាន់របស់វិនិយោគិន, ម្ចាស់អាជីវកម្ម, និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ ពីកាតព្វកិច្ចទាំងនេះនៅមានកម្រិត, កង្វះខាតអ្នកកត់ត្រាបញ្ជីគណនេយ្យ, អ្នកជំនាញគណនេយ្យ និងសវនកម្មក្នុងទីផ្សារ, និងវប្បធម៌គណនេយ្យ និងសវនកម្មមិនទាន់ចាក់ឫសរឹងមាំ។

*គោលដៅយុទ្ធសាស្ត្រ (Strategic objectives) នៃសសរស្តម្ភទី៤ គឺការលើកកម្ពស់គុណភាព ភាពត្រឹមត្រូវ តម្លាភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុរបស់សហគ្រាស អង្គភាពមិនស្វែងរកប្រាក់ចំណេញ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ស្ថាប័នសាធារណៈដោយអនុលោមតាមស្តង់ដាគណនេយ្យជាតិជាធរមាន។*

ដើម្បីសម្រេចបានគោលដៅយុទ្ធសាស្ត្រខាងលើនេះ សកម្មភាពជាយុទ្ធសាស្ត្រ ដែលត្រូវយកចិត្តទុកដាក់ រួមមាន៖ ១).ការបង្កើនមូលធនមនុស្សនិងពង្រឹងសមត្ថភាពមូលធនមនុស្សក្នុងវិស័យគណនេយ្យនិងសវនកម្ម តាមរយៈការជំរុញការបណ្តុះបណ្តាលអំពីស្តង់ដាបច្ចេកទេស និងឧបករណ៍អនុលោមភាពផ្សេងទៀត រួមទាំងការតម្រូវឱ្យសវនករ ថ្នាក់ដឹកនាំនិងបុគ្គលិកគណនេយ្យ/

សវនកម្មរបស់ក្រុមហ៊ុនគណនេយ្យនិងសវនកម្ម និងគណនេយ្យកររបស់សហគ្រាសនិងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ចូលរួមវគ្គបណ្តុះបណ្តាលស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្មនិងការអះអាង និងស្តង់ដាពាក់ព័ន្ធ,២).ការរៀបចំនិងដាក់ឱ្យអនុវត្តឧបករណ៍សម្រាប់គាំទ្រអនុលោមភាពដែលរួមមាន កម្មវិធីឃ្លាំមើល (Surveillance Program) គោលការណ៍បែបបទ នីតិវិធី និងឧបករណ៍ព័ត៌មានវិទ្យាផ្សេងទៀត, ៣).ការលើកកម្ពស់វប្បធម៌គណនេយ្យរបស់សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ, ៤).ការពិចារណាកែសម្រួលនិងស្នើដាក់ចេញវិធានគ្រប់គ្រងជាធរមាន និងបំពេញបន្ថែមដើម្បីលើកកម្ពស់កម្រិតអនុលោមភាព, ៥).ការរៀបចំនិងដាក់ឱ្យប្រើសទ្ទានុក្រមគណនេយ្យនិងសវនកម្ម និងការបកប្រែស្តង់ដាបច្ចេកទេសជាខេមរភាសា, ៦).ការពង្រឹងអនុលោមភាពបច្ចេកទេស (Technical compliance) និងអនុលោមភាពគតិយុត្តិ (Legal compliance), ៧).ការជំរុញការប្រើប្រាស់ថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល (Digital Financial Reporting Platform) ដើម្បីសម្រួលដល់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងដើម្បីកំណើនកម្រិតអនុលោមភាពខ្ពស់, ៨).ការលើកកម្ពស់កិត្តិនាមនៃស្ថាប័នវិជ្ជាជីវៈក្នុងក្របខណ្ឌអន្តរជាតិ តាមរយៈការរៀបចំឱ្យវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ទទួលបានជាសមាជិកពេញសិទ្ធិរបស់សហព័ន្ធគណនេយ្យករអន្តរជាតិ (IFAC) និង ៩).ការរៀបចំ និងដាក់ឱ្យអនុវត្តសៀវភៅណែនាំអំពីការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ (Manual for Financial Statement Review)។

### ៣.២.៥. សសរស្តម្ភទី៥៖ ការលើកកម្ពស់គុណភាពសវនកម្ម និងការអះអាង

ប្រព័ន្ធអេកូឡូស៊ីនៃការរាយការណ៍ហិរញ្ញវត្ថុបានដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យហិរញ្ញវត្ថុ និងបានរួមចំណែកក្នុងការចូលរួមលើកកម្ពស់បរិយាកាសធុរកិច្ចឱ្យប្រសើរឡើង និងកាន់តែងាយស្រួល និងជឿទុកចិត្តបាន ព្រមទាំងអាចកាត់បន្ថយថ្លៃដើមនៃការវិនិយោគ។ ជាតុសំខាន់ៗនៃប្រព័ន្ធអេកូឡូស៊ីនៃការរាយការណ៍ហិរញ្ញវត្ថុរួមមានដូចខាងក្រោម៖

- ការកំណត់ក្របខណ្ឌច្បាប់ដែលមានការឆ្លើយតបនិងមានភាពងាយស្រួលក្នុងការអនុវត្ត។
- ការធ្វើទំនើបកម្មស្តង់ដាពាក់ព័ន្ធនានា។
- ការរៀបចំនិងការបង្ហាញព័ត៌មានហិរញ្ញវត្ថុដែលអាចជឿទុកចិត្តបាន។
- ការផ្តល់និងការគ្រប់គ្រងអាជ្ញាបណ្ណ។
- ការគ្រប់គ្រងនិងការត្រួតពិនិត្យគុណភាពសវនកម្ម និងការអះអាងប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។
- ការជំរុញការអនុវត្តច្បាប់ និងការដាក់ទណ្ឌកម្មសមស្រប។

ក្នុងន័យនេះ **ន.គ.ស.** មានបេសកកម្មគ្រប់គ្រង និងត្រួតពិនិត្យការងារសវនកម្មរបស់ក្រុមហ៊ុនសវនកម្ម និងសវនកររូបវន្តបុគ្គលដែលមានអាជ្ញាបណ្ណត្រឹមត្រូវដើម្បីធានាបានភាពជឿទុកចិត្តបាន និងភាពត្រឹមត្រូវនៃរបាយការណ៍សវនកម្មឯករាជ្យ និងការអះអាង ព្រមទាំងការជំរុញការអនុវត្តច្បាប់និងការដាក់ទណ្ឌកម្មសមស្រប សំដៅការពារវិនិយោគិន ធុរជន និងសាធារណជននៅព្រះរាជាណាចក្រកម្ពុជា។ ដើម្បីសម្រេចបាននូវបេសកកម្មដែលបានកំណត់ **ន.គ.ស.** ដាក់ចេញនូវសសរស្តម្ភទី៥៖ ការលើកកម្ពស់គុណភាពសវនកម្មនិងការអះអាង។

*គោលដៅយុទ្ធសាស្ត្រ (Strategic objectives) នៃសសរស្តម្ភទី៥ គឺការគ្រប់គ្រងនិងការត្រួតពិនិត្យគុណភាពសវនកម្មនិងការអះអាង ដែលផ្តល់ដោយសវនករ អនុលោមតាមច្បាប់ បទប្បញ្ញត្តិ ស្តង់ដា និងក្រមសីលធម៌វិជ្ជាជីវៈដើម្បីធានាបានភាពជឿទុកចិត្តបាន និងភាពត្រឹមត្រូវនៃរបាយការណ៍សវនកម្មនិងរបាយការណ៍ការអះអាង សំដៅការពារវិនិយោគិន ធុរជន និងសាធារណជន។*

ដូច្នេះ ដើម្បីសម្រេចបានគោលដៅយុទ្ធសាស្ត្រនេះ សកម្មភាពជាយុទ្ធសាស្ត្រ ដែលនឹងត្រូវយកចិត្តទុកដាក់ រួមមាន៖ ១).ការរៀបចំយន្តការ និងក្របខណ្ឌនីតិកម្មគ្រប់គ្រងនិងត្រួតពិនិត្យគុណភាពសវនកម្មនិងការអះអាង, ២).ការធានាគុណភាពនិងឯករាជ្យភាពនៃការត្រួតពិនិត្យគុណភាពសវនកម្មតាមរយៈការធ្វើឱ្យប្រសើរឡើងនៃកម្មវិធីត្រួតពិនិត្យគុណភាពសវនកម្មនិងការអះអាង និងការកសាងសមត្ថភាពមន្ត្រីដើម្បីក្លាយជាអ្នកត្រួតពិនិត្យឯករាជ្យ, ៣).ផ្សព្វផ្សាយ និងការបង្កើនតម្លាភាពនៃរបាយការណ៍លទ្ធផលត្រួតពិនិត្យ, ៤).ការលើកកម្ពស់គុណភាពសវនកម្មតាមរយៈការបណ្តុះបណ្តាលសវនករជារូបវន្តបុគ្គល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនសវនកម្ម។

### ៣.២.៦. សសរស្តម្ភទី៦៖ ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យគណនេយ្យនិងសវនកម្ម

ការបង្កើតថ្នាលបច្ចេកវិទ្យាព័ត៌មានសម្រាប់វិស័យគណនេយ្យនិងសវនកម្ម ជាសសរស្តម្ភដែលមិនអាចខ្វះបានក្នុងការអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្ម ក្នុងបរិការណ៍សេដ្ឋកិច្ចឌីជីថល។ សកម្មភាពជាយុទ្ធសាស្ត្រមួយចំនួនត្រូវយកចិត្តទុកដាក់ និងរៀបចំតាមវិធានការគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដូចមានកំណត់ក្នុងគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា២០២៣-២០២៨។

ការប្រែប្រួលនិងការរីកចម្រើននៃវិស័យគណនេយ្យ និងសវនកម្មប្រព្រឹត្តទៅស្របគ្នានឹងការវិវត្តសេដ្ឋកិច្ច និងតម្រូវការអាជីវកម្ម តាមដំណាក់កាលនីមួយៗ ក្នុងនោះការប្រើប្រាស់បច្ចេកវិទ្យា-ហិរញ្ញវត្ថុ ក៏ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជួយអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្មនៅក្នុង

ប្រទេសកម្ពុជាផងដែរ។ ក្នុងន័យនេះ ការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល មានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុសម្រាប់វិស័យគណនេយ្យនិងសវនកម្ម ដែលតម្រូវឱ្យ **ន.គ.ស.** បានដាក់ចេញនូវសកម្មភាពជាយុទ្ធសាស្ត្រមួយចំនួនសម្រាប់ផែនការរយៈពេលខ្លី ដូចខាងក្រោម៖

- ការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល
- ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ
- ការជំរុញការអភិវឌ្ឍ និងនវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ។

*គោលដៅយុទ្ធសាស្ត្រ (Strategic objectives) នៃសសរស្តម្ភទី៦ គឺការកសាងបច្ចេកវិទ្យាគណនេយ្យ (Accounting Technology) និងសវនកម្មជាថ្នាលគ្រឹះ (Cornerstones) គាំទ្រសម្រាប់ជំរុញនវានុវត្តន៍ និងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដើម្បីសម្រេចបាននូវគោលបំណងនៃសេដ្ឋកិច្ចឌីជីថល។*

ដើម្បីសម្រេចបានគោលដៅនេះ សកម្មភាពជាយុទ្ធសាស្ត្រមួយចំនួនត្រូវបានដាក់ចេញ ដែលរួមមាន៖ ១). អភិវឌ្ឍបច្ចេកវិទ្យានិយ័តកម្មដើម្បីជួយ និងពង្រឹងអនុលោមភាពនិយ័តកម្មឱ្យកាន់តែមានប្រសិទ្ធភាព, ២). អភិវឌ្ឍ និងធ្វើទំនើបកម្មថ្នាលរបាយការណ៍ហិរញ្ញវត្ថុនិងចីរភាពឌីជីថល (Digital Financial and Sustainability Reporting Platform) ដើម្បីបង្កើនគុណភាពរបាយការណ៍ដែលស្របតាមស្តង់ដារជាតិនិងអន្តរជាតិ និងធានាអន្តរប្រតិបត្តិការជាមួយប្រព័ន្ធរបាយការណ៍ជាសកលដោយប្រើប្រាស់វចនានុក្រមគណនេយ្យ (Accounting Taxonomy) និងភាសារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (Extensible Business Reporting Language - XBRL), ៣). អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទិន្នន័យគណនេយ្យហិរញ្ញវត្ថុ (Accounting & Sustainable Disclosure Taxonomy) គាំទ្រការអភិវឌ្ឍបច្ចេកវិទ្យាគណនេយ្យ គោលការណ៍ផ្ទៀងផ្ទាត់ដោយស្វ័យប្រវត្តិ និងការវិភាគហិរញ្ញវត្ថុ (Financial Benchmarking), ៤). ជំរុញ និងប្រើប្រាស់ថ្នាលឌីជីថលគ្រឹះសម្រាប់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យគណនេយ្យនិងសវនកម្ម, ៥). រៀបចំ និងដាក់ឱ្យប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (Application Programming Interfaces - APIs) និងអន្តរប្រតិបត្តិការរវាងតួអង្គពាក់ព័ន្ធ ព្រមទាំងរៀបចំយន្តការលើការទទួលស្គាល់ប្រព័ន្ធបច្ចេកវិទ្យាគណនេយ្យដែលប្រើប្រាស់ដោយសហគ្រាស សម្រាប់កត់ត្រានិងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (List of Approved Accounting Software), ៦). រៀបចំ និងដាក់ឱ្យអនុវត្តន៍ក្របខណ្ឌការប្រើប្រាស់បច្ចេកវិទ្យាក្នុងក្រុមហ៊ុនគណនេយ្យនិងសវនកម្ម (Digital Adoption Framework for Licensed Accounting & Auditing Firms) ព្រមទាំង **ឋ.គ.ស.ក.** ៧). រៀបចំក្របខណ្ឌពាក់ព័ន្ធនឹងការវាយតម្លៃ និងគ្រប់គ្រង

ហានិភ័យបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យគណនេយ្យនិងសវនកម្ម, និង ៨). ការជំរុញការអភិវឌ្ឍនិងនវានុវត្តន៍អាជីវកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យគណនេយ្យនិងសវនកម្ម។

## ៤. យន្តការអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តយុទ្ធសាស្ត្រ

**ន.គ.ស.** គឺជាស្ថាប័ននាំមុខក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ ដោយត្រូវសហការ និងសម្របសម្រួលជាមួយស្ថាប័ននានា វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា, និយ័តករក្រោមឱវាទ **អ.ស.ហ.**, ក្រុមហ៊ុនគណនេយ្យ និងសវនកម្ម, អគ្គនាយកដ្ឋានពន្ធដារ, ក្រសួងអប់រំយុវជន និងកីឡា, ក្រសួងពាណិជ្ជកម្ម, គ្រឹះស្ថានអប់រំ, ស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធនានា។ **ន.គ.ស.** ត្រូវរៀបចំផែនការសកម្មភាពការងារលម្អិតដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រក្នុងដំណាក់កាលនីមួយៗ (រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង) ដើម្បីស្នើសុំការណែនាំតម្រង់ទិសពីក្រុមប្រឹក្សា **អ.ស.ហ.**។

អគ្គលេខាធិការដ្ឋាន **អ.ស.ហ.** មានភារកិច្ចក្នុងការសម្របសម្រួលជាមួយ **ន.គ.ស.** និងអង្គភាពពាក់ព័ន្ធផ្សេងទៀតលើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រនេះ ដើម្បីដាក់ជូនក្រុមប្រឹក្សា **អ.ស.ហ.** ពិនិត្យ និងតម្រង់ទិស។ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃត្រូវធ្វើឡើងវិញឈរលើមូលដ្ឋានប្រចាំឆ្នាំ ឬពាក់កណ្ដាល អាណត្តិ ឬតាមភាពចាំបាច់នៃការវិវត្តនៃវិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា។ ក្រុមប្រឹក្សា **អ.ស.ហ.** មានតួនាទីក្នុងការតាមដាននិងវាយតម្លៃលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រនេះ ដោយយោងតាមច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

**ន.គ.ស.** មានតួនាទីនិងភារកិច្ចរៀបចំរបាយការណ៍លទ្ធផលនៃការអនុវត្តផែនការសកម្មភាពការងារប្រចាំឆ្នាំ និងផែនការសកម្មភាពជាយុទ្ធសាស្ត្រតាមដំណាក់កាលនីមួយៗ ដើម្បីស្នើសុំការពិនិត្យ និងសម្រេចពីក្រុមប្រឹក្សា **អ.ស.ហ.**។

លទ្ធផលដែលបានមកពីការពិនិត្យនិងវាយតម្លៃរបស់ក្រុមប្រឹក្សា **អ.ស.ហ.** គឺជាមូលដ្ឋានដើម្បីកែសម្រួល និងធ្វើបច្ចុប្បន្នភាពនៃយុទ្ធសាស្ត្រ ដើម្បីធានាបាននូវប្រសិទ្ធភាពនិងសក្តិសិទ្ធភាព។

ផែនការសកម្មភាពបីឆ្នាំរំកិលនឹងត្រូវបានរៀបចំដើម្បីធានាប្រសិទ្ធភាពនិងសក្តិសិទ្ធភាព នៃការអនុវត្ត ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ។

## ៥. សេចក្តីសន្និដ្ឋាន

ជារួម ដើម្បីគាំទ្រដល់ការរីកចម្រើននៃសេដ្ឋកិច្ចកម្ពុជា និងដើម្បីអាចសម្របខ្លួនទៅនឹងការវិវត្តឥតឈប់ឈរនៃសេដ្ឋកិច្ចសកល និយ័តករគណនេយ្យនិងសវនកម្មនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ពិនិត្យឃើញថា ការដាក់ឱ្យអនុវត្ត "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា២០២៥-២០៣៥**" គឺជាត្រីវិស័យដើម្បីតម្រង់ទិសដល់និយ័តករគណនេយ្យនិងសវនកម្ម ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនឱ្យបានពេញលេញ និងចំទិសដៅនៃកំណែ-ទម្រង់ស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ក្នុងនីតិកាលទី៧ នៃរដ្ឋសភា ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០។

ការរៀបចំឡើងនូវឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា ក្នុងគោលបំណងសម្រេចឱ្យបាននូវគោលដៅចុងក្រោយគឺ "**ប្រព័ន្ធគណនេយ្យនិងសវនកម្មដែលរឹងមាំ មានតម្លាភាព និងអាចជឿទុកចិត្តបាន**" នៅព្រះរាជាណាចក្រកម្ពុជា ដែលយុទ្ធសាស្ត្រជាអាទិភាពត្រូវបានផ្តោតជាពិសេសលើការអភិវឌ្ឍស្ថាប័ន ការរៀបចំក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិ និងវិធានគ្រប់គ្រងវិស័យគណនេយ្យនិងសវនកម្ម ការបង្កើតយន្តការជានាអនុលោមភាព ការអភិវឌ្ឍមូលធនមនុស្សក្នុងវិស័យគណនេយ្យនិងសវនកម្ម ការលើកកម្ពស់គុណភាពសេវាសវនកម្ម និងការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាគាំទ្របច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងបរិការណ៍សេដ្ឋកិច្ច-ឌីជីថល និងមានរយៈពេល១០ឆ្នាំ ដែលចែកជា៣ ដំណាក់កាល គឺរយៈពេលខ្លី (២០២៥-២០២៧) រយៈពេលមធ្យម (២០២៨-២០៣០) និងរយៈពេលវែង (២០៣១-២០៣៥) ព្រមទាំងបានកំណត់នូវយន្តការតាមដាននិងវាយតម្លៃដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្ត។ **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា២០២៥-២០៣៥** នេះជាឯកសាររស់ដែលអាចនឹងត្រូវកែសម្រួលជាយថាហេតុ ដើម្បីសម្របទៅនឹងបរិការណ៍ជាក់ស្តែងនិងការវិវត្តសង្គម-សេដ្ឋកិច្ច ទាំងនៅក្នុងប្រទេស តំបន់ និងសកលលោក។

ក្នុងន័យនេះ ដើម្បីឱ្យការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មទទួលបានជោគជ័យតាមការរំពឹងទុក និយ័តករគណនេយ្យនិងសវនកម្មនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សង្ឃឹមយ៉ាងមុតមាំថា គ្រប់តួអង្គពាក់ព័ន្ធនឹងចូលរួមសហការយ៉ាងពេញលេញប្រកបដោយមនសិការវិជ្ជាជីវៈ និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់។

## ៦. បរិសិដ្ឋ

# ផែនការសកម្មភាពយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យគណនេយ្យនិងសវនកម្មនៅកម្ពុជា ២០២៥-២០៣៥ របស់និយ័តករគណនេយ្យនិងសវនកម្ម

| សកម្មភាពការងារ | រយៈពេលខ្លី (២០២៥-២០២៧) | រយៈពេលមធ្យម (២០២៨-២០៣០) | រយៈពេលវែង (២០៣១-២០៣៥) |
|---|---|---|---|
| **១. សសរស្តម្ភទី១៖ ការពង្រឹង និងពង្រីកសមត្ថភាពស្ថាប័ន** | | | |
| ១.១ ការពង្រឹងអភិបាលកិច្ចល្អនិងការគ្រប់គ្រងស្ថាប័ន | ត្រួតពិនិត្យនិងវិភាគមុខងារ, បំពេញបន្ថែមវិធានគ្រប់គ្រងនិងពង្រឹងការអនុវត្ត និងពង្រឹងរចនាសម្ព័ន្ធស្ថាប័ន។ | បន្តបំពេញបន្ថែមវិធានគ្រប់គ្រងនិងពង្រឹងការអនុវត្តនិងពង្រឹងរចនាសម្ព័ន្ធស្ថាប័ន។ | បន្តបំពេញបន្ថែមវិធានគ្រប់គ្រងនិងពង្រឹងការអនុវត្តនិងពង្រឹងរចនាសម្ព័ន្ធស្ថាប័ន។ |
| ១.២ ការរៀបចំរចនា-សម្ព័ន្ធចាត់តាំងនិងប្រព័ន្ធលើកទឹកចិត្ត | បំពេញរចនាសម្ព័ន្ធចាត់តាំងដែលនៅចន្លោះ និងអនុវត្តប្រព័ន្ធលើកទឹកចិត្តសមស្របដែលធានាបាននូវប្រសិទ្ធភាពនិងសក្តិសិទ្ធភាព។ | បន្តបំពេញរចនាសម្ព័ន្ធចាត់តាំងដែលនៅចន្លោះ (ករណីចាំបាច់) និងអនុវត្តប្រព័ន្ធលើកទឹកចិត្តសមស្រប ដែលធានាបាននូវប្រសិទ្ធភាព និងសក្តិសិទ្ធភាព។ | បន្តបំពេញរចនាសម្ព័ន្ធចាត់តាំងដែលនៅចន្លោះ (ករណីចាំបាច់) និងអនុវត្តប្រព័ន្ធលើកទឹកចិត្តសមស្រប ដែលធានាបាននូវប្រសិទ្ធភាព និងសក្តិសិទ្ធភាព។ |
| ១.៣ ការធានាបាននូវភាពគ្រប់គ្រាន់នៃធនធានមនុស្សនិងការកសាងសមត្ថភាពជំនាញ | ▪ បន្តបំពេញបន្ថែមចំនួនមន្ត្រីឱ្យបានគ្រប់គ្រាន់ និងរៀបចំបណ្តុះបណ្តាលជំនាញចាំបាច់ សម្រាប់អនុវត្តមុខងារនិងភារកិច្ច ទាំងជំនាញបច្ចេកទេស ជំនាញគ្រប់គ្រងនិងដឹកនាំ និងបច្ចេកវិទ្យា | ▪ បន្តបំពេញបន្ថែមចំនួនមន្ត្រីឱ្យបានគ្រប់គ្រាន់ និងរៀបចំបណ្តុះបណ្តាលជំនាញចាំបាច់ សម្រាប់អនុវត្តមុខងារនិងភារកិច្ច ទាំងជំនាញបច្ចេកទេស ជំនាញគ្រប់គ្រងនិងដឹកនាំ និងបច្ចេកវិទ្យា | ▪ បន្តបំពេញបន្ថែមចំនួនមន្ត្រីឱ្យបានគ្រប់គ្រាន់ និងរៀបចំបណ្តុះបណ្តាលជំនាញចាំបាច់ សម្រាប់អនុវត្តមុខងារនិងភារកិច្ច ទាំងជំនាញបច្ចេកទេស ជំនាញគ្រប់គ្រងនិងដឹកនាំ និងបច្ចេកវិទ្យា |

| សកម្មភាពការងារ | រយៈពេលខ្លី (២០២៥-២០២៧) | រយៈពេលមធ្យម (២០២៨-២០៣០) | រយៈពេលវែង (២០៣១-២០៣៥) |
|---|---|---|---|
| | ព័ត៌មានវិទ្យាក្នុងវិស័យគណនេយ្យនិងហិរញ្ញវត្ថុ។<br>▪ បន្តប្រើអ្នកជំនាញបច្ចេកទេសជាធនធានខាងក្រៅ។ | ព័ត៌មានវិទ្យាក្នុងវិស័យគណនេយ្យនិងហិរញ្ញវត្ថុ។<br>▪ បន្តប្រើអ្នកជំនាញបច្ចេកទេសជាធនធានខាងក្រៅ។ | ព័ត៌មានវិទ្យាក្នុងវិស័យគណនេយ្យនិងហិរញ្ញវត្ថុ។<br>▪ បន្តប្រើអ្នកជំនាញបច្ចេកទេសជាធនធានខាងក្រៅ។ |
| ១.៤ ការផ្តល់សេវាសាធារណៈឆ្លើយតបទៅនឹងបរិការណ៍សេដ្ឋកិច្ចឌីជីថល | បច្ចុប្បន្នភាពនិងអភិវឌ្ឍប្រព័ន្ធព័ត៌មាន-វិទ្យាសម្រាប់ធានាប្រសិទ្ធភាពនៃសេវាសាធារណៈ។ | បន្តបច្ចុប្បន្នភាពនិងអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ធានាប្រសិទ្ធភាពនៃសេវាសាធារណៈ។ | បន្តបច្ចុប្បន្នភាពនិងអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ធានាប្រសិទ្ធភាពនៃសេវាសាធារណៈ។ |
| ១.៥ កិច្ចសហប្រតិបត្តិការ | ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិក្នុងវិស័យគណនេយ្យនិងសវនកម្ម។ | បន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិក្នុងវិស័យគណនេយ្យនិងសវនកម្ម។ | បន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ ក្នុងវិស័យគណនេយ្យនិងសវនកម្ម។ |
| **២. សសរស្តម្ភទី២៖ កសាងមូលធនមនុស្សជំនាញគណនេយ្យនិងសវនកម្ម សម្រាប់ទីផ្សារ** | | | |
